មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយ ប្រាក់ សាម៉ុន ភេទប្រុស អាយុ៥៩ឆ្នាំ(កើតឆ្នាំ១៩៥៤)**

**មុខងារសម័យខ្មែរក្រហមៈ“យុទ្ធជនកងពល៨០១”**

**កើតនៅឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្ដាល**

**សព្វថ្ងៃរស់នៅភូមិអូររំដួល ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្ដរមានជ័យ**

**ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ ឌី ខាំបូលី**

**០១: ២៤ :១៧**

**៣១ទំព័រ**

បូលីៈ ដើម្បីកុំឲ្យខាតពេល ឥលូវខ្ញុំសុំថតសម្លេងអ៊ីជង ណាអ៊ី ខ្ញុំកត់អត់ទាន់! ខ្ញុំសុំស្គាល់ឈ្មោះអ៊ីជង ណាអ៊ី!

សាម៉ុនៈ ខ្ញុំឈ្មោះ ប្រាក់ សាម៉ុន!

បូលីៈ ប្រាក់ សាម៉ុន ។ សព្វថ្ងៃ អ៊ីអាយុប៉ុន្មានហើយ?

សាម៉ុនៈ ខ្ញុំ៦០ជាងហើយ ។ កើត១៩៥៤!

បូលីៈ ៥៤! ៦១ទេហើយអ៊ី?

សាម៉ុនៈ បាទ!

បូលីៈ អ៊ីមានស្រុកកំណើតនៅឯណាវិញ?

សាម៉ុនៈ ខ្ញុំនៅខេត្តកណ្ដាល!

បូលីៈ ស្រុកអីដែរ?

សាម៉ុនៈ ស្រុកស្អាង ។

បូលីៈ ឃុំ?

សាម៉ុនៈ ស្អាង ។

បូលីៈ ឃុំស្អាងភ្នំ ស្រុងស្អាង ខេត្តកណ្ដាល ។

សាម៉ុនៈ បាទ!

បូលីៈ កាលពីនៅតូចៗ អ៊ីនៅរៀនដល់ថ្នាក់ណាដែរ?

សាម៉ុនៈ ខ្ញុំរៀនបានត្រឹមថ្នាក់ទី៧ ។

បូលីៈ ហេតុម៉េចបានជាឈប់រៀន?

សាម៉ុនៈ កាលសម័យនោះមាន សភាពការយើង (ស្ដាប់ពុំបាន)តទៀតយើងក្រណាំ ហើយរៀនបានប៉ុណ្ណឹង ។

បូលី៖ ឈប់តាំងពីឆ្នាំណាអ៊ុំ?

សាម៉ុន៖ ឆ្នាំ៦៣ ។

បូលី៖ ៦៣ នៅក្នុងសម័យសង្គមរាស្ត្រនិយមនៅឡើយ?

សាម៉ុន៖ បាទ! ៦៣, ៦៤ បានឈប់ ។ ឈប់ហើយខ្ញុំ ឪពុកម្តាយខ្ញុំ ឲ្យខ្ញុំបួស ខ្ញុំបួសទៅរៀនខាងលោកសង្ឃ ។ រៀនដល់ឆ្នាំ៦៩ បានខ្ញុំឈប់ កាលនោះ ម្តាយខ្ញុំគាត់ឈឺខ្លាំង ។ ហ្នឹងស្លាប់ ៦៩ដែរ ។

បូលី៖ ហ៊ូយូរហើយចឹង ។

សាម៉ុន៖ ដល់គាត់ឈឺខ្លាំងចឹងអត់លុយកាក់អីមើលជំងឺគាត់! ហើយខ្ញុំអត់លុយរៀន លោកសង្ឃមែនតែប្រើលុយដូចតែគ្នា គ្រាន់តែយើងធូរមានព្រះចៅអធិការហ្នឹងជួយទៅ ។ ហើយកាលដែលខ្ញុំរៀននោះ ប្រលងធ្វើការបានដូចគ្នាបើយើងរៀនខាងសាលាបាលីណា ។ ហើយខ្ញុំប្រលងឪប្ដូររួចក៏ស្រុកគេកើតសង្គ្រាម!

បូលី៖ រដ្ឋប្រហារ ។ ក្រោយបីរដ្ឋប្រហាហើយយ៉ាងម៉េចទៀតទៅ?

សាម៉ុន៖ ពេលឆ្នាំ៧០ហ្នឹង រដ្ឋប្រហារហ្នឹង ។ ខ្ញុំយកគ្រួសារ ការ! កាលហ្នឹងនៅច្របូលច្របល់ណា៎ ការឆ្នាំ៧០ ។ ដល់៧១,៧២, ៧៣ កាលហ្នឹងទម្លាក់គ្រាប់គ្រាប់អីណា ។ នៅភូមិខ្ញុំហ្នឹង (ស្តាប់ពុំបាន) វាយចោល ។ គេធ្វើបាប ឪពុកម្តាយខ្ញុំ ខ្ញុំក៏ចូលធ្វើទាហាន ហ្នឹងគេ!

បូលី៖ ទាហានណាចាប់ឪពុកវាយចោល?

សាម៉ុន៖ ទាហានខាង លន់ នល់ ណា៎ ។

បូលី៖ ហេតុផលអីអ៊ុំ?

សាម៉ុន៖ ចោទ! ថាគាត់មេភូមិអីខ្មែរខាងខ្មែរក្រហមអីចឹងទៅណា៎ ចេះតែចោទទៅ ។ តាមពិត (ស្តាប់ពុំបាន) ដល់ចឹងឃើញចឹងសភាពការចឹង(ស្តាប់ពុំបាន) តែសងសឹកទេណា៎ ការពិតអត់មានគោលបំណងចង់ធ្វើអីទេ ប៉ុន្តែគ្រាន់តែ ខឹងចង់សងសឹងចឹង! ចូលធ្វើទាហានរំដោះជំនាន់នោះ គេងហៅទាហានរំដោះ៧៣! អាហ្នឹង កំពុងយន្តហោះទាហាន ទម្លាក់ខ្លាំងមែនទែន ចូលចឹងទៅ ដល់ពេល១៧មេសា ខ្ញុំនៅភ្នំពេញបានដាខ្ទង់កន្លះខែ ហើយគេបញ្ជូនមករតនៈគីរីអង្គភាពខ្ញុំ ។

បូលី៖ អង្គភាពណា?

សាម៉ុន៖ ៨០១ ។ បញ្ជូនមករតនៈគីរី! យើងឆ្នាំ៧៧នេះ គេយកគ្រួសារខ្ញុំទៅ ។

បូលី៖ យកទៅណា?

សាម៉ុនៈ យកទៅនៅរតនៈគីរីដែរ ។

បូលីៈ ចឹងពេលដែរអ៊ីទៅ គ្រួសារនៅឯក្រោយទេ?

សាម៉ុនៈ នៅៗ! ដល់ទៅនៅរតនៈគីរី៧៥ហ្នឹង គ្រួសារខ្ញុំនៅហ្នឹង ។

បូលីៈ នៅឯណាវិញ?

សាម៉ុនៈ នៅស្អាងយើងហ្នឹង! ភូមិតានង់ ឃុំស្អាងភ្នំ ស្រុកស្អាងខេត្តកណ្ដាល ។

បូលីៈ សុំកាត់ប្រសាសន៍អ៊ីតិច! ដែលអ៊ីចូល៧៣ហ្នឹង ស្អាងយើងនៅក្នុងតំបន់ប៉ុន្មាន?

សាម៉ុនៈ ចូល៧៣ស្អាងនៅតំបន់រំដោះគេហើយជំនាន់នោះ ។

បូលីៈ ឈ្មោះតំបន់អីគេ ពេលហ្នឹង តំបន់លេខប៉ុន្មាន?

សាម៉ុនៈ នៅស្អាង គេហៅតំបន់២៥ចេះ ។

បូលីៈ ២៥?

សាម៉ុនៈ បាទ! ២៥ ។ កាលហ្នឹង អត់ទាន់មានចូល ជាប់ភូមិភាគគាត់ ដល់ក្រោយមក ឆ្នាំប៉ុន្មាន ដែលរៀបចំភូមិភាគពិសេស ។ មានភ្នំពេញ(ស្ដាប់ពុំបាន) មានអី ខ្ញុំអត់សូវដឹងទេ! គ្រាន់តែថា ខ្ញុំចូលបន្ទាប់មក ។ បានធ្វើជាវរសេនាតូចទេ! យើងមានតែវរសេនាតូចធ្វើតាមមុខសញ្ញាទេណា៎ ធ្វើការតាមម៉ុកសញ្ញាដល់ឆ្នាំ៧៤! រៀបចំបង្កើតជាវរសេនាធំ ។

បូលីៈ ទើបតែវរសេនាធំ អត់ទាន់កងពលទេអ៊ី?

សាម៉ុនៈ វរសេនាធំ៥២ កាលហ្នឹង! ហ្នឹងវរសេនាតូចរបស់ខ្ញុំ១១ អនុសេនាធំ១៣ ។

បូលីៈ ចឹងពេលរៀបចំជាវរសេនាធំលេខប៉ុន្មានដែរទេ?

សាម៉ុនៈ វរសេនាធំលេខ៥២ ។

បូលីៈ ឈរជើងនៅម្ដុំណាដែរ?

សាម៉ុនៈ ឈរជើងយាមកាមដំបូងនៅ(ស្ដាប៉ពុំបាន) ។

បូលីៈ នៅក្នុងស្រុកអីគេ?

សាម៉ុនៈ នៅវាមែនទែនទៅ វានៅវាចល័ត ជួនអីមកយើងស្អាងនេះទៅ មកវាយយើងនៅស្អាង! ខំអីឈរជើងនៅមិននឹងនរទេ! មែនទែនមូលដ្ឋាន ឈរជើងជាប់ព្រះវៀមតាកែវហ្នឹង ស្រុកបាទីខេត្តតាកែវ ។ ចុងឆ្នាំ៧៤ បានគេបញ្ជូនមកវាយខាងជើងភ្នំពេញ ប៉ុន្តែខ្ញុំអត់បានវាយគេទេខ្ញុំ ។

បូលីៈ កងពលទៅ! បញ្ចូលកងពលទៅ?

សាម៉ុនៈ ដល់មកជើង បានបញ្ចូលកងពល១៤ តំបន់ខាងជើងភ្នំពេញ ។

បូលី៖	កងពលរបស់តា០៥?

សាម៉ុន៖	អត់ទេ! ០៥រងទេ មានគេប្រធាន ។

បូលី៖	នរណាគេប្រធាន ។

សាម៉ុន៖	សូ សារឿនហ្នឹងគាត់ ពីដើមគាត់នៅវរសេនាតូចហ្នឹង១១១ហ្នឹង គាត់!

បូលី៖	១១១ហ៎?

សាម៉ុន៖	បាទ! ខ្ញុំរៀបចំវរសេនាធំ៥២ហ្នឹងហើយបានមកដើងភ្នំពេញ បានដាក់កងពល១៨ ប៉ុន្តែខ្ញុំកាលហ្នឹងនៅរបួស បានហើយមកដើងភ្នំពេញ បានដាក់កងពល១៨ ។ ប៉ុនកាលហ្នឹងខ្ញុំត្រូវរបួស គេបង្កើតមុនដំបូង បង្កើតនៅតំបន់២៥ហ្នឹង កងពល១១ ដំបូងណ៎ ។ ចេញពីវរសេនាធំ៥២ហ្នឹងមក គេបង្កើត(ស្តាប់ពុំបាន)កើតកងពល១១ ។ កងពល១១ បានដកពួកខ្ញុំមួយវរៈធំនោះមកដាយភ្នំពេញ(ស្តាប់ពុំបាន) ។

បូលី៖	មកបង្កើត១៨?

សាម៉ុន៖	បាទ! មកចូលរួមគ្នា វរៈប៉ុន្មានៗទេនៅខាងដើភ្នំពេញ ។ ៣វរៈធំហ្នឹង! បង្កើតដូចជាកងពល១៨ចឹងណ៎ ។ ខ្ញុំអត់សូវស្គាល់វរសេនាធំទេណ៎!

បូលី៖	បាទ!

សាម៉ុន៖	ហើយយើង៧៥ហ្នឹងយើងវ៉ាយ វ៉ាយចូលភ្នំពេញនឹងណ៎! ធម្មតាខ្ញុំនៅជាយុទ្ធជនធម្មតាហើយនៅភ្នំពេញហើយ ។

បូលី៖	ចូលតាមច្រកណា ពេលវ៉ាយចូលភ្នំពេញហ្នឹង?

សាម៉ុន៖	ខាងខ្ញុំទិសដៅ ចូលព្រលានយន្តហោះ!

បូលី៖	ពោធិ៍ចិនតុង?

សាម៉ុន៖	ពោធិ៍ចិនតុង ស្អីគេនោះទួលគោក ។

បូលី៖	ខាងទួលគោកណ៎?

សាម៉ុន៖	បាទ! ហើយខ្ញុំនៅរបួសពេលហ្នឹង ដូចអត់បានវ៉ាយគេទេណ៎ ។ ខ្ញុំនៅពេទ្យស្រុកអង្គស្នួល ។ ខ្ញុំគ្រុន! គ្រុនមកដេកពេទ្យបានប៉ុន្មានថ្ងៃបែកភ្នំពេញ ។ ហើយកាលហ្នឹងខ្ញុំឈរវ៉ាយពួកខ្ញុំមានតែមួយត្រង់សេទេ ។ (ស្តាប់ពុំបាន)វ៉ាប្រើទ័ពតិចណា បើវ៉ាជុំវិញ មកឡើងគ្រុនគ្រុន៣ទៅ៤ថ្ងៃ ។

បូលី៖	អុំនៅម្តុំណាភ្នំពេញ?

សាម៉ុនៈ ចូលមុនដំបូងនៅផ្សារថ្មី ក្រោយមកបានមកនៅទួលគោក ចេញពីទួលគោកទៅរតនៈគិរីម្ដង ។

បូលីៈ នៅធ្វើអីម៉ុំទួលគោកផ្សារថ្មីហ្នឹង?

សាម៉ុនៈ នៅត្រៀមចេញ ព្រំដែន មានធ្វើអីផង ។

បូលីៈ ពេលហ្នឹងកងពល៨០១ គេប្រកាសនៅ?

សាម៉ុនៈ ៨០១ ចូលដល់ហ្នឹងធ្វើសន្និបាត ប្រកាសកងពល(ស្ដាប់ពុំបាន)

បូលីៈ មិនមែនប្រកាសនៅរតនៈគិរីទេ?

សាម៉ុនៈ ៨០១បង្កើតនៅហ្នឹង ។

បូលីៈ បាទ!

សាម៉ុនៈ បង្កើតនៅហ្នឹង(ស្ដាប់ពុំបាន)តែមួយវរសេនាតូចទេ យកពីនិរតី យកពីបូព៌ា យកពីឧត្ដរអីមកបូកចូលគ្នាណា បានមួយកងពល ។

បូលីៈ ពីណាអ្នកប្រកាសកងពលពេលហ្នឹងអ៊ុំ?

សាម៉ុនៈ ពីណាទេហ្នឹង កាលហ្នឹងខ្ញុំទៅធ្វើសន្និបាតហ្នឹង មិនហ្នឹងឃើញមេដឹកនាំធំៗផង មិនដឹងចាក់ធ្វើស្អី ធ្វើសន្និបាតនោះ ។

បូលីៈ មិនមែនតា សុន សេន ទេ?

សាម៉ុនៈ ប្រកាសកងពល អគ្គមេបញ្ជាការ ប៉ុន្ដែ(ស្ដាប់ពុំបាន) តាមពិត គេធំជាងអានេះតិច ។

បូលីៈ នរណាគេធំជាងនោះទៅទៀត?

សាម៉ុនៈ ខ្ញុំអត់ស្គាល់ទេ ។

បូលីៈ ធំជាងសុន សេន មានតែប៉ុល ពត ។

សាម៉ុនៈ (ស្ដាប់ពុំបាន) ខ្ញុំមិនដែលឃើញប៉ុល ពតយ៉ាងម៉េចផង ។

បូលីៈ ហើយគេប្រកាសថាម៉េចទៅពេលហ្នឹង?

សាម៉ុនៈ អត់ទេ! នៅសន្និបាត ប្រកាសបង្កើតកងពលហ្នឹងណា៎ កងពលផ្សេងៗទៀត គេប្រកាសឧទាហរណ៍ថារបស់ភូមិភាគពិសេសនោះវាមានប៉ុន្មានៗកងពលចឹងណា៎ ។ ហើយកងទ័ពរបស់មជ្ឈិមនោះមានប៉ុន្មានកងពល កងពលចឹងទៅមាន(ស្ដាប់ពុំបាន) ៨០០ ទៅ៩០០ ។ ៨០១!

បូលីៈ ៨០១?

សាម៉ុនៈ បាទ! សូ សារឿន ហ្នឹងគាត់គ្រប់គ្រងប្រធានកងពលណា៎ ។

បូលីៈ ពេលដែលចេញមករតនៈគិរីហ្នឹង យើងចេញមកប៉ុន្មានកងពល ចេញមកទាំងអស់គ្នា ឬក៏ចេញម្តងម្នាក់?

សាម៉ុនៈ ចេញទាំងអស់ ។ នៅតាមរយៈអើយ កាណូតគេមកសម្រាកនៅក្រចេះនោះណា៎ មកបានត្រឹមក្រចេះ ។

បូលីៈ កាណូតប៉ុណ្ណាអ៊ី?

សាម៉ុនៈ កាណូតធំ ។ អាកាណូត អាហ្នឹងគេមានសណ្តោងប៉ុក ចាយនៅក្រោយទៀតនោះណា៎ បើតាមពិត អាកាណូតនោះវាមានខ្លួនតូចណា ព្រោះវាអូសអាទូកធំណា៎ មកដាក់ស្បៀងដាក់អី ។

បូលីៈ កម្លាំងប៉ុន្មានពាន់កាលហ្នឹង មួយកងពល?

សាម៉ុនៈ មួយកងពលទាំងគ្រប់ស្ថាប័នធំៗទាំងអស់(ស្តាប់ពុំបាន) ។ គេរៀបចំសេដ្ឋកិច្ចមួយកងចឹងទៅ ខាងនារីមួយកងចឹងទៅ ហើយខាងកាំភ្លើងធំមួយកងចឹងទៅ ជុំវិញហ្នឹងប៉ុន្មានៗ មួយអគ្គភាព ជុំវិញកងពល ។ មានតាមវរៈធំ មានបីវរៈធំ ហើយខ្ញុំជិនោះនៅវរៈធំ៨១ ។

បូលីៈ វរៈធំនៅខាង វឹន សៃ?

សាម៉ុនៈ អត់ទេ! ខ្ញុំនៅសាលាខម អូរយាដាវណា៎!

បូលីៈ អូរយាដាវ?

សាម៉ុនៈ បាទ!

បូលីៈ ក្នុងរតនៈគិរីដែរ?

សាម៉ុនៈ បាទ! ក្នុងរតនៈគិរីដែរ ។

បូលីៈ ៨២នៅខាងស្ទឹងត្រែង?

សាម៉ុនៈ ៨២ សៀមប៉ាងខ្ញុំអត់ដឹងទេ វរៈគេ៨២ ទៅ៨៣ ខ្ញុំដឹងតែមុខសញ្ញាខ្លួនឯងទេ គេឲ្យទៅណាទៅហ្នឹង ។

បូលីៈ ពេលដែលមកហ្នឹងយើងសម្រាកនៅក្រចេះមួយថ្ងៃ?

សាម៉ុនៈ សម្រាកកន្លះខែនោះ បានឡើងទៅយក ។

បូលីៈ សម្រាកកន្លះខែ សម្រាកសុទ្ធតែម្តង ឬក៏ធ្វើអ៊ីទៀត?

សាម៉ុនៈ មានធ្វើអ៊ីទេ! ជួយច្រូតជួយបោកបែន អ្នកស្រុកនៅហ្នឹងណា៎ ចាប់តែកម្លាំងគេមកយកនៅក្រចេះ នៅកន្លែងក្រុង៣ថ្ងៃ នាំគ្នាដើរត្រឹមគម្ពីរមក ។

បូលីៈ អ៊ូ! នៅគម្ពីរ?

សាម៉ុនៈ នៅគម្ពីរនៅសម្រាកហ្នឹង ។

បូលីៈ ហើយបានផ្ទះសម្បែងណាសម្រាក?

សាម៉ុនៈ សម្រាកតាមក្រោមដើមឈើ តាមមាត់ទន្លេ ដើមស្វាយធំៗ យើងនៅក្រោមហ្នឹង ។

បូលីៈ ពេលហ្នឹងអ៊ុំ ឃើញប្រជាជននៅគម្ពីរ និងអ្នកមូលដ្ឋាននៅគម្ពីរដូចគ្នា?

សាម៉ុនៈ មានតា! មាននៅខាងចុង ខាងក្រោមៗប្រូតស្រូវប្រូតអីបត់បែនខ្ញុំណា៎ កាលតូចៗ ។

បូលីៈ នៅកន្លះបានឡានគេនមកយកនៅ?

សាម៉ុនៈ កាលហ្នឹងខាងលើគេឲ្យមកនៅ ព្រោះសម្បូរហូបផងត្រី ។ នៅគម្ពីរនោះធ្វើធ្លួសធ្វើអី!

បូលីៈ បាទ! យល់ហើយ ។

សាម៉ុនៈ ត្រីសម្បូរហូប ។ នៅកន្លែងក្រុងអី!

បូលីៈ ចុះក្រុងក្រចេះពេលដែលអ៊ុំទៅដល់ស្ងាត់ទេអ៊ុំ?

សាម៉ុនៈ មនុស្សច្រើនដែរតា ប៉ុន្តែគ្រាន់តែថា វាអត់អ្វីអរដូចពីមុនណា៎ បើរត់ចេញទៅនេះទៅនោះ ប៉ុណ្ណឹងវាមែនទែនទៅ វាសុខសាន្តមុន ខាងខ្ញុំនេះ នៅកៀកភ្នំពេញ ។

បូលីៈ ត្រូវហើយខាងនោះគេរំដោះមុន?

សាម៉ុនៈ បាទ! ខាងជើងគេរំដោះមុន មែនទែនទៅគេបានរស់នៅស្រួល ធ្វើស្រែ ធ្វើសម្ការអីស្រួលបើខាងខ្ញុំផង ស្ងួនយប់ ពេលយប់បានស្ងួន ។

បូលីៈ ដល់ពេលអ៊ុំទៅរតនៈគីរី ដំបូងយើងទៅដលនណា៎សិន ទៅអូរយាដាវភ្លាម ឬក៏?

សាម៉ុនៈ ខ្ញុំនៅតែនេះ នៅតែបរកែវ ។

បូលីៈ នៅបរកែវ?

សាម៉ុនៈ បាទ! ស្នាក់នៅបរកែវនេះបានប៉ុន្មានថ្ងៃ គេយកទៅនៅឯសាលាក្រហម គេហៅសាលាក្រហមណា៎ ។

បូលីៈ ស្រុកអី?

សាម៉ុនៈ អត់ស្គាល់ស្រុកទេ ខ្ញុំមិនដឹងទេមែនទែនទៅ វាជាប់ស្រុកបរកែវដែរ ដឹងហើយហ្នឹង ឬក៏អណ្តូងមាស ។ ខ្ញុំមិនសូវស្គាល់ទេ! មិនដឹងថាកន្លែងនៅឈ្មោះអីៗ បើអាស្រុក តែកាលហ្នឹងជំនាន់ហ្នឹង ឈ្មោះស្រុកដូចយើងឥលូវណា៎ ម- ប៉ុន្មានៗ ខ្ញុំមិនសូវស្គាល់អីទេ ។

បូលីៈ គេដាក់លេខសំងាត់?

សាម៉ុនៈ ហ្នឹងហើយ!

បូលីៈ ហើយអ៊ុំនៅហ្នឹង រហូតដល់៧៩ហ្នឹង ឬមានការផ្លាស់ប្តូរទៅខាងណា៎ទៀត?

សាម៉ុនៈ ដល់អើ! ៧/៨ហ្នឹង បានខាងកងទ័ពវៀតណាមហ្នឹង សម្រុកមកខ្លាំង! គ្រួសារខ្ញុំគេរត់មុន នោះធ្លាក់ទៅដល់ឯនោះ ដល់ពាយ័ព្យ ។ (ស្តាប់ពុំបាន) គេថាទៀបបារាំងអីយ៉ាងម៉េច នោះ ទៅដល់ហ្នឹង ខ្ញុំទៅដល់ហ្នឹងគ្រួសារខ្ញុំ ហើយខ្ញុំមានអីដល់ទៅគេនេះ បុកខ្លាំង ប្រាលទៅ បុកទៅឯនោះវិញ ។

បូលីៈ បុកទៅខេត្តរបស់?

សាម៉ុនៈ របស់យួនណា៎ ។ បាទ! យើងចូលទៅនោះ វាអត់មានកងទ័ព ចឹងយើងវាងពីក្រោយគេ ណា៎ ។ បើកាលនៅរត់ក្រោយបេះមិនរត់ទេ ។

បូលីៈ យួនវាយបុកមកម៉េចក៏មិនរត់ទៅយួនវិញអ៊ុំ?

សាម៉ុនៈ យើងវាងមុខគេណា៎ ។

បូលីៈ គេវាយទៅដល់ក្នុងហើយណា៎?

សាម៉ុនៈ បាទ! គេទៅបុកខ្លាំងមែនទែន តាមព្រំដែននោះ បុកណា៎ ។

បូលីៈ យួនបុកមក?

សាម៉ុនៈ បាទ!

បូលីៈ ហើយកងទ័ពខ្មែរក្រហមយើង ម៉េចក៏ចូលទៅបុកគីវិញ?

សាម៉ុនៈ វាងៗទៅ សសៀរៗតាមព្រំដែនយើង ប៉ុនអាហ្នឹងគេហៅអីបុកគីនោះ ។

បូលីៈ អ៊ុំកន្លែងនេះអូរយាដាវណា៎អ៊ុំ ព្រំដែនណា៎អ៊ុំ ហើយនេះអណ្តូងមាស សុទ្ធតែពីរហ្នឹង សុទ្ធតែខ្មែរក្រហមដូចគ្នា ។

សាម៉ុនៈ ចុះបើយើងមើលអាស្រុកបកែវហ្នឹង ស្រុកអីចឹងអី ឈ្មោះស្រុកបរកែវ?

បូលីៈ បាទ! បរកែវមានឈ្មោះស្រុកបកែវ នេះវឺនសៃ នេះអណ្តូងមាស នេះខ្ញុំនៅបរកែវ ។ បរកែវនៅឆ្ងាយពីព្រំដែនអូរយាដាវ បានជិតព្រំដែនមែនទែន ។

សាម៉ុនៈ បាទៗ! កាលនោះយើងនៅអូយាដាវ គេហៅសាលាក្រហម ភាសាស្រុកគេហ្នឹង ប្រហែលជាភូមិ ។

បូលីៈ ឃុំអីតាមមើល?

សាម៉ុនៈ គេមានភូមិប៉ក់តូច ប៉ក់ធំ អីម៉េចគេទេ?

បូលីៈ បាទ! គេមាន! ហើយនេះផ្សវគូ ឌុកគឿ អុងថាងអីតាមមើល ។

សាម៉ុនៈ គ្រាន់តែយើង មិនទៅដល់ស្រុកគេទេ គ្រាន់តែសសៀរៗតាមហ្នឹងវាងក្រោយគេមកណា៎ ។ ធ្លាក់យើងមកនេះ ស្អីគេហៅប្រី មួយដូរប្រីមួយដូរអី ។ មកដល់ប្រី បានយើងចូលមកឆ្លង

ស្រែពកមកមណ្ឌលគិរីបាទឆ្លងពី     មកពីមណ្ឌលគិរីឆ្លងមករតនៈគិរីបានឆ្លងតាមផ្លូវ១៩មកនេះមក ។

បូលីៈ     អ៊ូ! ចឹងធ្លាក់មកមណ្ឌលគិរីវិញនេះអ៊ុំនេះ?

សាម៉ុនៈ     បាទ! ធ្លាក់មកមណ្ឌលគិរីហើយ បានឆ្លងតាមយើងអាស្រែពកនេះមកវិញ ។

បូលីៈ     ទន្លេស្រែពក?

សាម៉ុនៈ     ទន្លេស្រែពកមកឆ្លង១៩មកលិចមក ។

បូលីៈ     មកខាងណាវិញអ៊ុំ?

សាម៉ុនៈ     មកខាងយើងវិញ មកសេកុងយើងដដែរ ម្តុំសេសានហ្នឹង មកមួយផ្លូវហ្នឹង ។

បូលីៈ     មកឈប់ស្រុកអីវិញ វិនសៃអី?

សាម៉ុនៈ     មកស្រុកអី! អាហ្នឹងចូលស្ទឹងត្រែង ។

បូលីៈ     ចូលស្ទឹងត្រែងហើយ ។ ចូលស្ទឹងត្រែង មានតែសៀម ប៉ាង?

សាម៉ុនៈ     សៀម ប៉ាង មានតែលើទេ ។

បូលីៈ     មានតែលើទេណ៎?

សាម៉ុនៈ     នេះក្រោមនៅជិត ភូមិញូវៗ ។

បូលីៈ     ភូមិញូវអាចនៅ ជាឡាបរិវាត់ទេអ៊ុំ?

សាម៉ុនៈ     មិនដឹងស្រុកអីទេ យើងអត់សូវស្គាល់ ។

បូលីៈ     ហើយពេលណា បានអ៊ុំឡើងទៅភ្នំ?

សាម៉ុនៈ     ដល់មើលខ្ញុំនៅហ្នឹងប្រហែលជា ១ឆ្នាំ ។ ដល់ឆ្នាំ៨០! ហ្នឹងអត់ទាន់ដឹងគេនៅខាងណាៗ គេចេះដើរមកទៅណ៎ា ដើររកជួប ថ្នាក់ដឹកនាំគេហ្នឹង មកៗ ព្រោះខ្ញុំនៅភូមិហ្នឹង ស្អីទេ!

បូលីៈ     ១០០១?

សាម៉ុនៈ     គេហៅច្រកប្រោកៗនោះណ៎ា!

បូលីៈ     ប្រោក!

សាម៉ុនៈ     ដូចជាខាងលិចក្បាលអូរស្វាយនោះ ខាងកើតជាំយើង ខាងកើតជាំស្រងាំនេះណ៎ា ។

បូលីៈ     ចឹងអ៊ុំមក១០០៣នេះចឹង?

សាម៉ុនៈ     បាទ! កាលហ្នឹង ឡើងមក មិនមែន១០០៣?

បូលីៈ     ៨០១ កងពលក្រែងនៅ១០០១ហ៎?

សាម៉ុនៈ ទេ! អាហ្នឹងបែកគ្នាអស់ហើយ ព្រោះខ្ញុំឡើងភ្នំមកគេបំបែក លែងៗនៅជាប់៨០១ហើយ ។

បូលីៈ អ៊ុំនៅឯណា៎វិញ?

សាម៉ុនៈ នៅនេះយើង មកបង្កើតកងទ័ព មុនគេហៅ១០០២ទេចឹងដឹង ។

បូលីៈ ១០០២, ៦១២!

សាម៉ុនៈ កាលហ្នឹងគេដាក់១០០១ទេ ក្រោយមក(ស្តាប់ពុំបាន) តែក្រោយមកបានដាក់ប្រុកនេះ ១០០២ ។ ១០០២នេះចំ ត្រពាំងគូត្រពាំងអីហ្នឹង! ទី២ចំ!

បូលីៈ ពូចង់ឱ្យបង្ហាញ១០០២ហ្នឹងណៅម្តុំណា ព្រោះខ្ញុំអត់ច្បាស់ទេ១០០២ហ្នឹង?

សាម៉ុនៈ ១០០២ហ្នឹងយើងតិចទេ បានចេញពីហ្នឹងមកនៅ១០០៣វិញណា៎ ។

បូលីៈ តើមានប្រុកមួយណា៎ទៀ(ស្តាប់ពុំបាន)? មានប្រុកណាផ្សេង? នៅម្តុំនេះ (ស្តាប់ពុំបាន) នេះប្រាសាទព្រះវិហារ ។

សាម៉ុនៈ ហ្នឹងហើយអូននេះប្រុក អានសេះហ្នឹងឯង ពួកខ្ញុំនៅអាកន្លែងអានសេសហ្នឹងណា៎ ។

បូលីៈ មកខាងនេះវិញ?

សាម៉ុនៈ បាទ! មកខាងលិចវិញ ។

បូលីៈ អាហ្នឹងគេហៅអីវិញ?

សាម៉ុនៈ ភ្នំស្អីទេ! ចុះតាមប្រុកហ្នឹងវាចំកំពីងពួយ ដាំក្បាន្តយើងនេះ ។

បូលីៈ ក្បែរប្រាសាទព្រះវិហារ?

សាម៉ុនៈ អីកើតនោះ ។

បូលីៈ ខាងកើតព្រះវិហារនោះទៀត?

សាម៉ុនៈ បាទ!

បូលីៈ អ្ហូ! ចឹងបានន័យថា ។

សាម៉ុនៈ យើងនេះនោះម្តុំ គេហៅប្រាសាទអ្នកបួស ប្រាសាទអីនោះ ។ នៅមួយហ្នឹងយើង នៅខាងលិចអាពើយព្រិចៗណា៎! អាហ្នឹង៧០០ម៉ែត្រ កំពស់វាណា៎ មានតែអាហ្នឹងខ្ពស់ជាងគេ គ្រាន់តែយើងវានៅខាងលិចនេះ ខាងលិចនេះ ។

បូលីៈ ខាងលិចនោះទៀត?

សាម៉ុនៈ បាទ! ប៉ុន្តែយើងនៅខាងលិចនេះ ។ គេហៅវត្តស្អីគេនោះ! ដល់នៅនោះបញ្ហា វាមានបញ្ហាយើងខ្មែរសេរី ។

បូលីៈ ខ្មែរសេរីខ្មែណា?

សាម៉ុនៈ គេហៅជុំរុំបក្សីចាំក្រុងយើង ជុំរុំអានសេសអីហ្នឹង ។

បូលីៈ ខាងតាសឹន សាន?

សាម៉ុនៈ បាទ! ដល់ចឹងចេះតែលួចចុចមិនចុចអីចឹងទៅពួកខ្ញុំចេញពីហ្នឹងមកវិញ ។

បូលីៈ ចឹងជុំរុំបក្សីចាំក្រុងហ្នឹងនៅក្បែរអានសេសអីអុំ?

សាម៉ុនៈ បាទ!

បូលីៈ ចឹងយើងទោះបីយើងអត់ដឹងថា១០០២ នៅម្តុំណាច្បាស់លាស់ ប៉ុន្តែដឹងតែ!

សាម៉ុនៈ ហ្នឹងហើយ នៅម្តុំ!

បូលីៈ នៅខាងកើតប្រាសាទព្រះវិហារ ។

សាម៉ុនៈ បាទ!

បូលីៈ ហើយនៅខាងលិចច្រកអានសេសមិនចឹងអុំ?

សាម៉ុនៈ បាទ!

បូលីៈ ចឹងបានន័យថានៅចន្លោះនេះ?

សាម៉ុនៈ បាទ!

បូលីៈ មួយណា យើងកុំទាន់កំណត់ណា?

សាម៉ុនៈ អាហ្នឹង យើងមើលអូរសម្បូរ!

បូលីៈ ប៉ុនឲ្យមែនទែនថាដូចថា១០០២ហ្នឹងដូចថា!

សាម៉ុនៈ អាហ្នឹងចុងខាងជើងជាំក្សាន្តតែម្តងអុំចាំតែម្តង នៅកន្លែងពើយតែម្តង ។

បូលីៈ នៅខាងជើងជាំក្សាន្ត?

សាម៉ុនៈ បាទ!

បូលីៈ នេះទីរួមស្រុកណាអុំណា! ផ្លូវនេះចាក់ទៅអានសេស ។ នេះផ្លូវនេះ! ចាក់មកអានសេសផ្លូវនេះ ។ អាលូវនេះវាប្រាសាទ១,២,៣!

សាម៉ុនៈ បាទ! មានប្រាសាទអ្នកបួស ប្រាសាទស្អី ៗ ។

បូលីៈ ដល់ចឹងទៅវាមិនមែនចំនុចនេះចេះទេ! ១០០២ហ្នឹងវាដូចថា កងទ័ពនៅរាយប៉ាយនៅតាមព្រំដែន រហូតអីអុំ? ឬក៏យើងមាននៅម្តុំណាមួយ?

សាម៉ុនៈ យើងអត់ទេ! ជំនាន់នោះយើងរាយនៅមួយកង ៗ ចឹងទៅណា នៅតាមព្រំដែន ។

បូលីៈ មួយកងនៅនេះទៅ ៗ ?

សាម៉ុនៈ បាទ! យើងគម្ងាតគ្នាត្រឹម១គីឡូ ឬ២គីឡូអីចឹងទៅណា៎?

បូលីៈ បាទ! ចឹងមិនមែនមានមូលដ្ឋានឈរជើងធំអីច្បាស់លាស់ទេ? រាយតាមព្រំដែនចឹង?

សាម៉ុនៈ រាយ! ប៉ុន្តែ មីងៗកាលហ្នឹងដឹក អង្គរវាមានកន្លែងគេនៅម្តុំចឹងទៅ ប៉ុន្តែយើងមិនទៅនៅដីគេទេ នៅក្នុងទឹកដីយើង ។

បូលីៈ ១០០២ មានមីងៗដែរ ឬក៏កងទ័ពសុទ្ធ?

សាម៉ុនៈ មីងៗមាន! នៅក្រោយ នៅគេហៅវត្តជិតវត្តស្ពឺទេ គ្រួសារខ្ញុំនៅបានគាត់ចាំ ។

បូលីៈ ចឹង១០០២ចាប់ពីប្រាសាទព្រះវិហារមក ១០០២ជាអ្នកកាន់កាប់ម្តុំហ្នឹង?

សាម៉ុនៈ បាទ!

បូលីៈ នៅខាងមុខអីពូ?

សាម៉ុនៈ បាទ! ដល់មកប្រាសាទព្រះវិហារនៅខាងលិច របស់យើងច្រកព្រះវិហារ ព្រះប្រឡាយ ។

បូលីៈ ច្រកព្រះប្រឡាយឈូករុននេះ ។

សាម៉ុនៈ បាទ! យល់ ។

បូលីៈ ប៉ុនពេលអ៊ុំ រត់បីរតនៈគីរីមក ពេលហ្នឹងអ៊ុំនៅព្រៃមួយរយៈសិន មិនចឹង ហើយបានអ៊ុំរត់ឡើងភ្នំ?

សាម៉ុនៈ បាទ! យើងនៅមួយជួរស្ពឺ សេកុង សេសានហ្នឹង ខាងកើតមេកុងនោះ ។ ទៅនៅហ្នឹងបានក្រោយមក យើងដើររក មិនពួកថ្នាក់ដឹកនាំគេមិនរៀបចំដើររកគេ ។ ទៅដល់ស្ពឺ! នៅអាលិចនោះ ខ្ញុំទៅយក គេហៅច្រកស្ពឺ(សួរប្រពន្ធ)? អ៊ូ! ៨០៨ហ្នឹងហើយ ខ្ញុំឡើងយើងច្រកនេះទៅ ទៅដល់៨០៨ហ្នឹង គ្រួសារខ្ញុំនៅហ្នឹងដែរ ។

បូលីៈ ប្រោកនៅនេះៗ ។

សាម៉ុនៈ ប្រោកនៅម្តុំអូរស្វាយ!

បូលីៈ ខាងលិចអូរស្វាយ?

សាម៉ុនៈ បាទ!

បូលីៈ អានេះអូរស្វាយហើយអ៊ុំ បើអានេះប្រោក ហើយ៨០១នៅនេះ ត្រពាំងតាវនេះ ។

សាម៉ុនៈ ព្រោះយើង ឡើងពីប្រោកនោះដើរតាមព្រមដែននោះមក ។

បូលីៈ ដើរមកខាងលិចនោះមក(ស្តាប់ពុំបាន) ។

សាម៉ុនៈ មកពីសេកុង! (ស្តាបពុំបាន) ។ ជំហាននេះមួយយើងមកនេះនែក មកអើយ៨០១ហ្នឹងណា៎ ។

បូលី៖ ៨០៨?

សាម៉ុន៖ បាទ! ៨០៨ហ្នឹងជួបគ្រួសារ ជួបអីខ្ញុំទៅហ្នឹង ហើយក៏ត្រលប់មកវិញ បញ្ជូនមកអន្លុកភាព អីវិញ មកជួបអន្លុកភាពវិញទៅក៏យើងចាប់ផ្ដើមឡើង(ស្ដាប់ពុំបាន) ។

បូលី៖ អន្លុកភាពពួពេលហ្នឹងនៅឯណា?

សាម៉ុន៖ នៅខាងកើតមេគង្គនោះ ។

បូលី៖ ពេលហ្នឹងនៅ៨០១នៅឡើយទេ?

សាម៉ុន៖ បាទ! នៅ៨០១ ។

បូលី៖ ចឹងអ៊ុំមកជួបប្រពន្ធសិន?

សាម៉ុន៖ បាទ!

បូលី៖ ពេលបានមកជួបហើយ បានបកមកវិញ ៨០១នៅខាងទន្លេមេគង្គវិញ?

សាម៉ុន៖ បាទ!

បូលី៖ បន្ទាប់មកយ៉ាងម៉េចទៀត?

សាម៉ុន៖ បាននាំកម្លាំងហើយយើងមកដាប់ធ្វើការនៅមួយជួរ(ស្ដាប់បុំបាន) ព្រះនគ្គ័ល ។ ព្រះនគ្គ័ល នៅភូមិស្អី ព្រះឥន្ទកំពង់ស្មេនោះណា៎ ។

បូលី៖ បាទ! នៅស្រុកថាឡាបរិវ៉ាត់ ។ នៅម្ដុំនេះៗ!

សាម៉ុន៖ យើងធ្វើការបានន័យថាមិនមែននេះទេ ធ្វើការហ្នឹងមើលផ្លូវទេ ផ្លូវសម្រាប់នាំមកណា៎ ហើយចឹងទៅបានខាងលើភ្ជាប់គ្នា១០០១ ទៅ១០០២ចឹងណា៎គេរៀបចំ ។ ដំបូងគេនៅ ១០០២ទេ! ប៉ុន្ដែ១០០១ អត់ទាន់មានទេ ទាល់តែពួកខ្ញុំឡើងតាម១០០១ហ្នឹងមក អាហ្នឹង អត់ទាន់មានដាក់ឈ្មោះ១០០១ទេ ហើយកន្លែងដែលខ្ញុំនៅខាង១០០២គេហៅ ១០០១មុនដំបូងណា៎ ។ កម្លាំងគេដឹកស្បៀងអី សម្ភារផ្សេងៗ គេមកគេស្តុបមកដាក់នៅ ហ្នឹង ។ មកមួយទីហ្នឹង ព្រោះខ្ញុំឡើងពីក្រោមមកទាក់ទងត្រឹមៗនេះឯង ទាក់ទងហ្នឹងហើយ បានខាង៨០១ ឡើងមកអស់ នៅដាប់ហ្នឹងមុំបីហ្នឹង វាក៏ដាក់៨០១ហ្នឹងវិញ ១០០១ ។

បូលី៖ ពេលណាអ៊ុំចូលទៅ៦១២?

សាម៉ុន៖ ឆ្នាំ៨២ ។

បូលី៖ យ៉ាងមេចបានចឹងអ៊ុំ?

សាម៉ុន៖ ៨២ យើងចូលគ្នានេះ ណាមកធ្វើការនៅនេះហើយ ហ្នឹងវាមានកងពល៦១៦ហ្នឹងគាត់ ដូចថា វាមានគ្រោះថ្នាក់ច្រើន ហើយកម្លាំងវាដូចអត់សូវទប់ទល់ជាមួយ(ស្ដាប់ពុំបាន)ក៏

គាម៉ុកហ្នឹងឯងគាត់បញ្ជាពួកខ្ញុំមក ឲ្យមកនេះ ។ មកនៅ៦១២ហើយ រៀបចំចម្រុះ វាកងទ័ព មកពីក្នុង ៗមកណាស់ មកពីក្រចេះមកយើងហ្នឹងមកបញ្ចូលគ្នាបាន៦១២ហ្នឹង ។ ហើយកម្លាំងខ្ញុំតែមួយវរសេនាតូចទេ៦១២ហ្នឹងនោះ ។

បូលី: អ៊ុំធ្វើអ៊ីដែរ អនុប្រធានវរសេនាតូច?

សាម៉ុនៈ ខ្ញុំកាល៨២នោះ មិនទាន់មានបានធ្វើអីទេ កាលហ្នឹងគេឲ្យខ្ញុំដូចជាមេក្រុមអីចឹងណា៎ ។

បូលី: ហើយគេឲ្យវាយណា៎អ៊ុំ៦១២?

សាម៉ុនៈ នៅតាមព្រំដែន នៅ៦១២អត់បានចុះទេ ។

បូលី: នៅតាមនេះរហូត ។ អត់បានចុះមកផ្ទាល់ទេ?

សាម៉ុនៈ ចុះមក! កងផ្សេងៗចុះ តែពួកខ្ញុំនៅជាប់ហ្នឹងព្រំដែន មិនបានចុះអីទេ ។

បូលី: ពេលដែលចុះៗ មកចុះមកខេត្តណា៎វិញ?

សាម៉ុនៈ កាលហ្នឹង គេចុះមកទន្លេសាបនេះ ។

បូលី: ទន្លេសាប ។

សាម៉ុនៈ ទន្លេសាប ពួកខ្ញុំចេញពីហ្នឹងមកកងទៅឲ្យរៀបចំ កងទន្លេសាបហ្នឹង គេរៀបមួយកង ផ្សេងទៀត មួយចម្រុះទៀតពីខាងកំពង់ឆ្នាំងខាងកំពង់ធំ កំពង់អីបូកចូលគ្នាចឹងទៅណា៎ ទៅជា៧៨៥ទៅណា៎ កងពលគេហ្នឹងនោះ ។

បូលី: ៧៨៥ កើតក្រោយ៦១២ទេនោះ?

សាម៉ុនៈ កើតក្រោយ អាហ្នឹងដកតាមអង្គភាពផ្សេងៗមកកើតនៅហ្នឹងដែរ ។ ហើយខាងខ្ញុំហ្នឹង ត្រូវ កងពិតប្រាកដនៅជាប់ អត់មានទៅណា៎ទេ នៅជាប់ ។

បូលី: (ស្តាប់ពុំបាន)

សាម៉ុនៈ អាហ្នឹង ខ្ញុំយកហើយ យកមកពី៨០៨មក ។

បូលី: ៨០៨ណា៎?

សាម៉ុនៈ បាទ! យកមកៗ យកមក១០០២ហ្នឹង ។

បូលី: មកនៅ១០០២តែម្តង?

សាម៉ុនៈ បាទ!១០០២ ពេលចេញពី១០០២ ហ្នឹងបានមក១០០៣ ព្រះប្រឡាយហ្នឹងហើយ ហ្នឹងកាល៨២ណា៎ ។ ចឹងទៅយកគាត់មក ឆ្នាំ៨១!

បូលី: ៨២ រហូតដល់៨៩ ពូនៅហ្នឹងរហូត ឬក៏មានចុះមកក្នុងដែរ?

សាម៉ុនៈ យើងនៅក្រោមនេះ នៅតាហាននេះ ប៉ុននៅឯក្រោម ។ នេះប្រកព្រះប្រឡាយ ។

បូលី៖ ពូនៅប្រកណា៎? ព្រះប្រឡាយ ចឹងពូមកនៅ១០០៣ហើយចឹង?

សាម៉ុន៖ បាទ! អាហ្នឹង៨២ណា៎ ។

បូលី៖ ចុះទៅនៅ១០០២?

សាម៉ុន៖ ១០០២ ឆ្នាំ១៩៨១,៨២ ។ ដើម៨២មក ១០០៣ ។

បូលី៖ មកនៅកន្លែងណា៎វិញ?

សាម៉ុន៖ អាហ្នឹងហើយមកៗប្រជុំគ្នានៅកន្លែងហ្នឹង រៀបចំ៦១២ ។

បូលី៖ កាលហ្នឹងខ្ញុំនៅ៨០១ ដល់ខ្ញុំនៅ នោះ៨០១ ?

សាម៉ុន៖ កាលហ្នឹង៨០១ហើយ មានកម្លាំងនៅធ្វើការហ្នឹងណា៎ ។

បូលី៖ មុន៦១២ទៀត?

សាម៉ុន៖ បាទ! មុន៦១២ ។ ដល់តែយើងរៀបចំមកធ្វើការនៅប្រកព្រះប្រឡាយនេះមកបានរៀបចំ ៦១២ ។

បូលី៖ រៀបចំ៦១២ចឹង! ៦១២ កើតឆ្នាំ៨២ទេ?

សាម៉ុន៖ បាទ! ៨២ ។

បូលី៖ នរណាគេ(ស្តាប់ពុំបាន) ដំបូងបំផុត?

សាម៉ុន៖ អត់ស្គាល់ទេ!

បូលី៖ ពូប្រាប់ឈ្មោះមេចាស់? តាឈាន!

សាម៉ុន៖ តាឈាន ស្អីឈាន!

បូលី៖ ស្អីឈាន?

សាម៉ុន៖ ឈាន! ប៉ុន្តែដឹងតែត្រកូលអីទេ ។

បូលី៖ តាហឿន?

សាម៉ុន៖ តាហឿន! ឡើងក្រោយទេ ។

បូលី៖ ចឹងអ៊ុំមកនៅប្រកព្រះប្រឡាយហ្នឹង ចឹងបានន័យថាអានេះប្រកឈូករុនហ៎?

សាម៉ុន៖ ហ្នឹងហើយ ឈូករុន ។

បូលី៖ ចុះនេះ?

សាម៉ុន៖ នេះនៅឯក្រោយហ្នឹង ជាំស្វា! គេហៅស្អីម្ដុំ៥០អី ។

បូលី៖ អូរ៥០ ។

សាម៉ុន៖ អូរ៥០ ។

បូលីៈ ចឹងម៉េចក៏នៅអូរ៩០នេះវិញ?

សាម៉ុនៈ បាទ!

បូលីៈ ហើយពូចូលក្នុងម៉្ងៃះ?

សាម៉ុនៈ ខ្ញុំនៅឯក្នុងនេះ ។

បូលីៈ មកធ្វើការនៅនេះ?

សាម៉ុនៈ បាទ!

បូលីៈ កាលហ្នឹង មានវាយប៉ះយួនខ្លះទេនៅនេះ?

សាម៉ុនៈ គ្រាន់បើដែរហ្នឹងណា៎ ។ ៨០ប៉ុន្មានវាយព្រះប្រឡាយ ៨៤? ៨៤! ៨៤វាយ២ដង ក្នុងមួយឆ្នាំ ។ កាលហ្នឹងខ្ញុំទៅក្នុងនោះ ខ្ញុំទៅតាមតាម ឈានហ្នឹងណា ខ្ញុំនៅច្រកជាមួយហ្នឹងគាត់ ។

បូលីៈ ពេលទៅក្នុង ទៅខាងណាវិញ?

សាម៉ុនៈ ទៅជីក្រែង!

បូលីៈ មកខាងសៀមរាបវិញ?

សាម៉ុនៈ សៀមរាប ។ ទៅនៅកន្លែងគាត់នៅមន្ទីរ ។

បូលីៈ បាទ! យើងមកធ្វើការនៅនេះអ៊ុំ?

សាម៉ុនៈ បាទ!

បូលីៈ ធ្វើការខាងអី?

សាម៉ុនៈ ខាងនេះដកអាមួយវរៈតូចមកធ្វើការហ្នឹង ។

បូលីៈ ខាងផ្លូវជាតិលេខ៦ ។

សាម៉ុនៈ បាទ!

បូលីៈ ឆ្ងាយមកដល់ទន្លេសាបទៀតទេអ៊ុំ?

សាម៉ុនៈ ទន្លេសាបក្រុមគេផ្សេងទៀត!

បូលីៈ ខាងអ៊ុំនៅក្រោយផ្លូវជាតិលេខ៦ទៀត?

សាម៉ុនៈ អានេះក្រោម ខ្ញុំនៅឯជើងនេះ ។

បូលីៈ ជើងទៀត ។ មកប៉ុន្មានឆ្នាំ បានឡើងទៅមួង?

សាម៉ុនៈ ទៅជួនអី១ឆ្នាំ ។ មកមួយឆ្នាំ បានឡើងទៅមួង!

បូលី៖ មួយឆ្នាំ បានឡើងទៅវិញម្តង ៗ នៅពេលដែលយួនវាយបែកឆ្នាំ៨៤ នោះ វាយព្រំដែនហ្នឹងអ៊ុំនៅខាងក្រោមនេះ?

សាម៉ុន៖ នៅក្នុងនេះ! នៅក្នុងហើយបាន កាលនោះតាម៉ុក គាត់ហៅកម្លាំងឡើងមក មកខ្ញុំនៅដេកបានមួយយប់ ព្រលឹមឡើងដឹកទៅទៀត ៗ

បូលី៖ តាម៉ុក ឡើងលើវិញ?

សាម៉ុន៖ មកជួយវាយយួន?

បូលី៖ បាទ! ហើយយ៉ាងម៉េចទៀត?

សាម៉ុន៖ ដល់វាយមួយសារក្រោយនោះបែកមែនទែន ៗ

បូលី៖ វាយឃាត់ឲ្យនៅតែម្តង?

សាម៉ុន៖ បាទ! អស់ហើយមីង ៗ ធ្លាក់នៅជាំស្លានោះ ៗ

បូលី៖ ធ្លាក់មកជាំស្លានោះ?

សាម៉ុន៖ បាទ!

បូលី៖ នៅដីថៃ?

សាម៉ុន៖ ជាំស្លានៅបានប៉ុន្មានទេ ឲ្យមកនៅអីយើងស្អីជាំ(ស្តាប់ពុំបាន) ហៅគ-៧ ស៊ីងចាន់ ស៊ីងអីនេះវិញ! យើងនេះទេ នៅជាប់ដីយើងនោះទេ ប៉ុន្តែពួក៨០១ មកនៅគ-៧ហ្នឹងហើយ ៗ

បូលី៖ ៨០១ នៅគ-៧ ហ៎អ៊ុំ?

សាម៉ុន៖ បាទ!

បូលី៖ ដែលបែកពី១០០១មក?

សាម៉ុន៖ បាទ! ព្រោះខ្ញុំនៅឯមុខនោះ នៅជាំស្លាឯមុខនោះ ហ្ន៎! ឯជនពិការខាងមុខនោះទេ ប្រហែលជាប៉ុន្មានគីឡូពីគ-៧នេះទេ ៗ ខ្ទង់៣ទៅ៤គីឡូ!

បូលី៖ ហើយពេលដែលយើងអស់ដីនៅ យើងបន្តវាយទៀតទេអ៊ុំ?

សាម៉ុន៖ ជំនាន់នោះកម្លាំងដែលមែនទែនទៅ ជម្លៀសតែមីង ៗ ទេ មីង ៗ ចេះតែដើរយកដាក់កើតនោះ ៗ

បូលី៖ ដាក់កើតយ៉ាងម៉េចទៅអ៊ុំ?

សាម៉ុន៖ អត់ទេ! មីង ៗ ជម្លៀសចេញទៅឆ្ងាយទេពីកន្លែងវាយគ្នា ៗ

បូលី៖ កងទ័ពនៅបន្តវាយទៀត?

សាម៉ុន៖ បាទ!

បូលីៈ ឆ្នាំណាដែលយើងវាយបានអន្លង់វែង ត្រពាំងប្រាសាទវិញ?

សាម៉ុនៈ ប៉ុន្មានទេ! កាលវាយយកអន្លង់វែងអន្លង់អី ព្រះប្រឡាយយើងវិញឆ្នាំប៉ុន្មានទេ ។ បើតាមខ្ញុំដឹងមីង១ចុះពីលើមក មកនៅប្រកព្រះប្រឡាយឆ្នាំ៩០ ។

បូលីៈ ៩០គត់មែនទេអ៊ុំ?

សាម៉ុនៈ បាទ!

បូលីៈ ពេលដែលចុះមក ចុះមកជុំរុំ ឬក៏ចុះជាំស្រង៉ាំ ។

សាម៉ុនៈ ចុះតាមឈូករុន!

បូលីៈ តាមឈូករុននេះ?

សាម៉ុនៈ បាទ! កាលហ្នឹងមីង១នៅជាំស្វា យកមកដាក់នៅជាំស្វា ។

បូលីៈ មុនពេលដែលយើងចុះមកមានប្រជុំគ្នារៀបគម្រោងចុះមកដែរទេអ៊ុំ?

សាម៉ុនៈ អត់ទេ! ដូចជាចុះមកតែម្តង ។ ចេះតាមខ្ញុំដឹងទេណា តាំងពីផ្សព្វផ្សាយ កាលហ្នឹងយើងមិនត្រូវគ្នា ។ ត្រីភាគីហ្នឹងចុះមកធ្វើការនៅក្នុងស្រុកខ្មែរយើងនៅ មានស្នាក់មានអីហើយកម្លាំងហ្នឹង ខាងលើណែនាំថា កុំឲ្យមានគំនុំជាមួយថៃអីហ្នឹងណា៎ រួចទៅគេធ្វើបាបនរណាអី ហើយទី២ទៀត ខ្លាចពួកមីង១អត់ចេះធ្វើស្រែ ធ្វើអីណា៎ ។ ព្រោះគាត់នៅគាត់មិនស៊ីអង្ករស្រាប់ ស្លៀកពាក់ស្រាប់ ។ ដល់ចឹងខ្លាចអត់ចេះធ្វើស្រែ ធ្វើអីក៏ឆ្នាំ៩០ហ្នឹង ចុះមក! ចុះមកធ្វើស្រែ ធ្វើអីណា៎! ចឹងខ្ញុំធ្វើស្រែប្រកព្រះប្រឡាយ ។

បូលីៈ ចឹងចុះមក ចុះមកធ្វើស្រែព្រះប្រឡាយទេ?

សាម៉ុនៈ បាទ! សំខាន់ណាស់ ព្រះប្រឡាយនោះ?

បូលីៈ បាទ! មានដលល់ពេលព្រះប្រឡាយនោះមានរត់ចេញ?

សាម៉ុនៈ មាន៩០ប៉ុន្មាន! បោះឆ្នោតហើយណា៎ ។

បូលីៈ ៩៨អីបោះឆ្នោតហើយ?

សាម៉ុនៈ បាទ! ៩៨ហើយ!

បូលីៈ យ៉ាងម៉េចទៅ៩៨ហើយ?

សាម៉ុនៈ ៩៨ហ្នឹង ទៅនៅក្បាលអូរជីកនោះ ។

បូលីៈ ក្បាលអូរជីក អូរស្វាយយើងហ្នឹង?

សាម៉ុនៈ ប៉ុន្តែខ្មែរក្រហមយើងថាអូរល្ហុង១យើងណា៎ តាមពិតក្បាលអូរជីកចឹងឯង ពួកកម្លាំងតា០៥ជុំគ្នានៅហ្នឹង ។

បូលីៈ ហើយចុះពេលហ្នឹងកម្លាំងរដ្ឋាភិបាលវាយឆ្ពាយពីព្រះប្រឡាយមកទំនប់ដាច់ យ៉ាងម៉េចទៅចឹង?

សាម៉ុនៈ វាយគ្រាន់តែគ្រប់គ្រងអាកន្លែងច្រកហ្នឹង ប៉ុន្តែពួកខ្ញុំនៅនោះអត់ទេ ។ អត់ទៅដល់ទេ!

បូលីៈ វាយបានតែតិចៗចឹង?

សាម៉ុនៈ បាទ!

បូលីៈ មិនអាចឈានចូលដល់ជ្រៅទេណ៎?

សាម៉ុនៈ អត់ទេ! មែនទែនទៅ៨៤ គ្រាន់តែវាយ តែអត់បានគ្រប់គ្រងផងៗ ពួកខ្ញុំមកវិញដដែរហ្នឹង កម្លាំងទាហានមកធ្វើការទាហានដែរហ្នឹង ហើយមីនៗនៅនោះ ។

បូលីៈ ចឹងរដ្ឋាភិបាល បំបែកទេ?

សាម៉ុនៈ អត់បំបែក ។

បូលីៈ ខាងនេះមាំល្អណាស់ណ៎អ៊ុំ?

សាម៉ុនៈ បាទ!

បូលីៈ បើកុំតែមានការចាប់ខ្លួន កុំអីអត់បែកទេ?

សាម៉ុនៈ កម្លាំង! បើសិនជា មិនមានការបែកបាក់ផ្ទៃក្នុងទេ មិនងាយទេ ។ ហ៊ុនសែន ក៏គាត់ថាដែរ ព្រោះគាត់ជិះយន្តហោះកាលជំនាន់មកសមាហរណកម្ម គាត់គ្រាន់តែឃើញ(ស្តាប់ពុំបាន) គាត់ក្រវីក្បាល ។ ហើយទាហាននោះ ពេលជួនមក វង្វេងគ្នាត្រឹមព្រៃស្អាងនេះ បានមកដល់ ។

បូលីៈ មិនដឹងតំបន់ណាៗ!

សាម៉ុនៈ បាទ! ម្យ៉ាងទៀតតែវង្វេងគ្នានៅក្នុងព្រៃ តែអត់ដឹងពីកន្លែងទៅដឹងតែងាប់ហើយ ។ វាមិនស្រួលទេព្រៃស្អាកហ្នឹងគេដើរហ្នឹង សុទ្ធតែដើរចំកន្លែងទឹកកន្លែងអីណា ។ បើថាអត់ចំកន្លែងទឹកទេ មួយថ្ងៃវាល់ល្ងាច អត់មានឃើញទឹកទេ ។

បូលីៈ ចឹងបានវាយចូលអត់បាន វាខ្វះអាកន្លែងផ្តល់ទឹក ផ្តល់អាហារ ។

សាម៉ុនៈ បើមែនទែនទៅមួយជំនាន់នោះ និយាយពីរឿងប៉ុល ពត ថ្នាក់ដឹកនាំលើទៀត គេឈប់ច្បាំងឈប់អី ។ យ៉ាប់តាម៉ុកនេះមួយ មនុស្សអ្នកស្រែយ៉ាប់ណាស់ណ៎ ។

បូលីៈ យ៉ាប់យ៉ាងម៉េចទៅអ៊ុំ?

សាម៉ុនៈ កាលហ្នឹងខាងលិចអីគេមិនដាក់ គេមិនដាក់អី ចូលឃ្លាំងអស់ ។

បូលីៈ ខាងណ៎?

សាម៉ុនៈ មួយដួរខាងលិចហ្នឹង ។

បូលីៈ បាទ!

សាម៉ុនៈ គេមិនដាក់អស់?

បូលីៈ បាទ!

សាម៉ុនៈ នៅតែកន្ទែងតាម៉ុកហ្នឹងឯង ។

បូលីៈ ចុះតា ប៉ុល ពត កាលហ្នឹង?

សាម៉ុនៈ តាប៉ុល ពតកាលហ្នឹង! ដាក់វាហើយមិនគាត់ផែនការគាត់មិនចង់មកចូលរួមសង្គមជាតិវិញណា៎ពីជំនាន់នោះ គាត់របៀបថាគ្រួសារតឹងរបៀបចូលរួមជាសមាហរណកម្ម ទៅជាមួយសង្គមជាតិវិញនោះ ជំនាន់នោះផែនការហ្នឹង ផែនការពួកបដិវត្តន៍នេះគេឆ្លាតគេចឹង ប៉ុន្តែអ្នកស្រែនោះគេយ៉ាប់តែឯងតែម្តងវីង ។

បូលីៈ ផែនការនោះយ៉ាងម៉េចយ៉ាងម៉េច ប៉ុល ពតហើយហ្នឹងពួកបញ្ញាវ័ន គេប្រុងចុះចូល?

សាម៉ុនៈ ចុះចូលរដ្ឋាភិបាល គេបង្រួបបង្រួមមានមាគ៌ាមួយបង្រួបបង្រួមជាតិផ្សះផ្សាជាតិចឹង បញ្ចប់សង្គ្រាម ។ កាលហ្នឹងក្រោយពីឆ្នាំ៨០ប៉ុន្មាន! ដូចជា៨៨ទេ វៀតណាមដកចេញពីស្រុកខ្មែរយើងណា៎!

បូលីៈ ៨៩?

សាម៉ុនៈ បាទ! ៨៧,៨៨,៨៩ ចឹងណា៎?

បូលីៈ បាទ!

សាម៉ុនៈ ដកចេញបីឆ្នាំ ។ ៨៩ហ្នឹង ផែនការប៉ុល ពត មិនបញ្ឈប់ ចូលជាមួយរដ្ឋាភិបាល ដល់ចឹងតាម៉ុកនេះ អត់ព្រម! មានតែឯង ។

បូលីៈ ចឹងមិនមែនតាម៉ុកអ្នកចូលទេ ប៉ុល ពតគ្រប់គ្រងទេ?

សាម៉ុនៈ ដល់ ប៉ុល ពត គាត់តែឯង គាត់ម៉េចហាន គាត់តាម៉ុកនៅវីង កម្លាំងមែនទែនទៅ ភាគច្រើនកម្លាំងតាម៉ុកមិនចឹង?

បូលីៈ បាទ!

សាម៉ុនៈ ប៉ុល ពត មានកម្លាំងឯណា៎! មានតែកម្លាំងតាម៉ុក ដល់ចឹងឃើញតាម៉ុកចឹងម៉េចហាន ។

បូលីៈ មានធ្លាប់មានការចរចាគ្នាទេ? ចរចាជាមួយរដ្ឋាភិបាលណា?

សាម៉ុនៈ ជំនាន់នោះចរចា ជួបគ្នានៅប្រាសាទព្រះវិហារ ប៉ុន្តែកម្លាំងបែកឆ្វេងពីតាម៉ុកហ្នឹងគេជំទាស់ចឹងណា៎ ។ កាលហ្នឹងមិន ទៅទាំងអស់គ្នាហ្នឹងហើយ! តាំងពីឆ្នាំប៉ុន្មានទេកាលហ្នឹង!

បូលីៈ ៩០ជាង! ៩៧ អីហើយ។

សាម៉ុនៈ ខ្ទង់៩៦!

បូលីៈ ៩៦?

សាម៉ុនៈ បាទ! ខ្ទង់៩៦ ។ កាលនោះមិនខាងថ្ងៃ៥ ទៅថ្ងៃ៦! ៩៦ចឹង?

បូលីៈ ៩៧! ៥ ទៅ៦កក្កដា,៩៧ នៅខាងភ្នំពេញ ។

សាម៉ុនៈ ហ្នឹងហើយ! ជំនាន់ហ្នឹងកំពុងសារ៉េចូលទាំងអស់ហើយតាមខ្ញុំដឹងទេណ៎ ។

បូលីៈ ពីណាគេប្រុង? តាម៉ុក ឬក៏តាប៉ុល ពត?

សាម៉ុនៈ ប៉ុល ពត! រឿងខ្វាស់តាម៉ុក ហ្នឹងហើយបានវាយ៉ាប់ជំនាន់ហ្នឹង ។

បូលីៈ អ៊ុំថាចរចានៅប្រាសាទព្រះវិហារហ្នឹង ខាងណា៎ អ្នកគេផ្តើមចរចា ខាងតាម៉ុក ឬខាងប៉ុល ពត?

សាម៉ុនៈ ខាងនេះទាំងអស់គ្នាហ្នឹងឯង ទាំងខាងតាម៉ុក ទាំងតា ប៉ុល ពត ណា៎ ។

បូលីៈ ប៉ុន អ្នកណាមេគំនិត?

សាម៉ុនៈ មេគំនិត ប៉ុល ពត ។

បូលីៈ ពីណាគេអ្នកទៅចរចាផ្ទាល់តាមមើល?

សាម៉ុនៈ អាហ្នឹងតាសួ្ញ មុន ទេ ។

បូលីៈ ខាំ មុន?

សាម៉ុនៈ បាទ! គាត់ហ្នឹងឯង ។ កាលហ្នឹងមិនឯកឧត្តម ភា អីគាត់អញ្ជើញមក! ភា នោះ ខ្ញុំនៅក្រោម ។

បូលីៈ អ៎ូ! ពេលចរចាទាហានហ្នឹងហ៎េ?

សាម៉ុនៈ បាទ! អាហ្នឹងចុងក្រោយហើយទេ និយាយគ្នា ។ ពេលដល់អត់ត្រូវគ្នាទៅ នៅវៀ៉ោ ទៀតទៅណា៎ ។

បូលីៈ ពេលហ្នឹងចាប់ខ្លួន ប៉ុល ពត នៅ? នៅទេ?

សាម៉ុនៈ បាទ! នៅ ។

បូលីៈ ពេលហ្នឹង ឮសួរថាខៀវសំផន ទេព ខាណាន់អីទៅចរចាដែរ?

សាម៉ុនៈ ហ្នឹងហើយ ខ្ញុំនៅហ្នឹងឯង ។

បូលីៈ ជំនាន់នឹង ។ ហើយខាងភាគីរដ្ឋាភិបាល ពីណាគេ?

សាម៉ុនៈ ឯកឧត្តម មាស សុភា ហើយក្រោមៗទៀតពីណាគេទេ ព្រោះខ្ញុំនៅក្រោមខ្ញុំអត់ដឹង ។

បូលី៖	មាស សុភា! ខាងគណបក្សប្រជាជន ចុះហ៊ុន សុិនប៊ុិចមានទេ ខាងនៅចរចាព្រះវិហារនេះ?

សាម៉ុន៖	ដូចអត់មានទេ។ ទេ! ដូចមាន ញឹក ប៊ុនឆៃ។

បូលី៖	ញឹក ប៊ុនឆៃមកដែរ?

សាម៉ុន៖	ញឹក ប៊ុនឆៃមកដែរ។ កាលនោះខ្ញុំនៅកន្លែង៩៦ ខ្ញុំអត់បានមកទេ។

បូលី៖	ប៊ុន ញឹក ប៊ុនឆៃ ឮសូរថាចរចានៅខាងនេះវិញទេ នៅខាងរមៀត។

សាម៉ុន៖	ហ៊ូ! គោករមៀត?

បូលី៖	បាទ! គោករមៀតចឹងហ៎អឹ?

សាម៉ុន៖	អាហ្នឹងជំនាន់ហ្នឹង ជំនាន់ចាប់យន្តហោះ ចាប់អីហ្នឹង។

បូលី៖	បាទ! អាជំនាន់ចាប់យន្តហោះណ៎។

សាម៉ុន៖	ឆ្នាំប៉ុន្មានទេនេះ។ ខ្ញុំអត់ដឹង នៅកើតនោះ!

បូលី៖	ពេលហ្នឹងអត់ទាន់នេះទេ តាប៉ុល ពត និងតាម៉ុក អត់ទាន់វាយគ្នាទេ ញឹក ប៊ុនឆៃមកចរចា ប៉ុនភាគីខាងតាម៉ុក មិនមែនភាគីតាប៉ុល ពតទេណ៎ ហើយបើចរចាលើប្រាសាទព្រះវិហារ ប្រហែលជាខាងតាប៉ុល ពតចរចា មិនមែនតាម៉ុកទេ។

សាម៉ុន៖	បាទ!

បូលី៖	ចឹងវាអាចប្រទាំងប្រទិសគ្នាពីរហ្នឹង។

សាម៉ុន៖	ហ្នឹងហើយខ្សែតាម៉ុក អត់ឯកភាពណ៎។

បូលី៖	ប្រហែលចេះទេអុិ អាចខ្សែតាម៉ុកចរចាជាមួយហ៊ុន សុិនប៊ុិច! ដល់ពេលខ្សែតាប៉ុល ពតចរចាជាមួយគណបក្សប្រជាជន។ ដល់ពេលគណបក្សប្រជាជន និង ហ៊ុនសុិនប៊ុិចនៅជាមួយរដ្ឋាភិបាលចម្រុះណ៎។ កាលហ្នឹងសម្ដេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី១ ដល់សម្ដេចហ៊ុន សែន នាយករដ្ឋមន្ត្រីទី២! អុំមានដឹងរឿងនេះទេ?

សាម៉ុន៖	ឮគេចរចា អត់ៗដឹងទេ។ ព្រោះរឿងហ្នឹង ខ្ញុំនៅអត់ទាន់ដឹងច្បាស់នៅឡើយ បើថាត្រូវសរសេរយ៉ាងមេចណាអុំ! ទាក់ទងទៅហ្នឹងការចរចាហ្នឹង។ ខាងណាអ្នកផ្ដួចផ្ដើម ខាងណាអ្នកជំទាស់ ខាងណាអ្នករាំង ខ្ញុំចឹងណ៎។ បាទ! វាអត់សូវដឹងទេ គ្រាន់តែថាឮសូរល្បៀងៗមកឈ្មោះ ផន់ នោះគេជំទាស់។

បូលី៖	ហេតុអីបានជាគេជំទាស់ កាលនោះ?

សាម៉ុនៈ	កាលនោះដូចមិនត្រូវរឿងគ្នា មិនដឹងយ៉ាងណា៎! ឬមួយក៏យ៉ាងណាទេ វាចង់បំផ្លាញ ប៉ុល ពត វាមិនថាអី ដូចជាយ៉ាងម៉េចទេ បែបគោលគំនិតវាចឹងហើយតាមមើល ។

បូលីៈ	ពេលដែរស៊ុន សេនស្លាប់ តើពូដឹងថានរណាអ្នកសម្លាប់ស៊ុន សេនទេ?

សាម៉ុនៈ	(ស្តាប់ពុំបាន)

បូលីៈ	ខាងភាគី តាម៉ុក ឬភាគីតាប៉ុល ពតតាមមើល?

សាម៉ុនៈ	មិនដឹងយ៉ាងម៉េចទេ ពិបាក! បានតាមដានអាការ ៦១២ កងពល៦១២ នៅខាងណា ។

បូលីៈ	ខ្ញុំនៅឯនេះនោះ នៅខាងកើត នៅព្រះវិហារនោះ ។ ខ្ញុំនៅព្រះវិហារនោះ ។

អ្នកជិតខាងៈ	គាត់នៅខាងកើតនោះ អត់ដឹងផង!

បូលីៈ	អត់បានមកចូលរួមវាយហ្នឹងគេទេ?

សាម៉ុនៈ	អត់ទេ!

បូលីៈ	មានបញ្ជាឲ្យមកចូលរួមជួយទេ?

សាម៉ុនៈ	អត់ទេ! គ្រាន់តែគេប្រាប់ឲ្យនៅការពារប្រាសាទព្រះវិហារ មែនទែនទៅផ្ទៃក្នុងវារញ៉េរញ៉ៃ ខ្លាចរដ្ឋាភិបាលវាយ វាយយកប្រាសាទព្រះវិហារហ្នឹងណា៎ គ្រាន់តែការពារចឹងឯង ហើយ អាគេយ៉ាងណា៎ យ៉ាងណី អត់ដឹងរឿងទេ ។

បូលីៈ	អ៊ំនៅប្រាសាទយើងនេះទេ?

សាម៉ុនៈ	បាទ!

បូលីៈ	អ៊ំនៅឈរជើងការពារប្រាសាទលើនោះតែម្តង?

សាម៉ុនៈ	បាទ! ខ្ញុំខាងវិទ្យុទាក់ទង ។

បូលីៈ	អ៊ុំឈរជើងនៅម្តុំណា?

សាម៉ុនៈ	ខ្ញុំនៅប្រាសាទទី៤!

បូលីៈ	ប្រាសាទទី៤?

សាម៉ុនៈ	បាទ!

បូលីៈ	ពេលហ្នឹងខាងខ្មែរក្រហមយើង កាន់កាប់ប្រាសាទព្រះវិហារនៅឆ្នាំណា៎ដែរ?

សាម៉ុនៈ	ឆ្នាំប៉ុន្មានទេ ដូចកាន់បាន៤ឆ្នាំ ។ ខ្ញុំទៅនៅហ្នឹង៤ឆ្នាំ! មិនពីឆ្នាំណាមកទេ ។

បូលីៈ	ពី៨០ជាងមកខាងខ្មែរក្រហម ឬក៏ខាងរដ្ឋាភិបាលកាន់កាប់?

សាម៉ុនៈ	ខាងរដ្ឋាភិបាល ។

បូលីៈ	ចុះពេលបោះឆ្នោតឆ្នាំ! តលូវចរចាសន្តិភាពបារីសឆ្នាំ៩១ហើយ ខាងណាកាន់កាប់?

សាម៉ុនៈ នៅរដ្ឋាភិបាលកាន់កាប់ ។

បូលីៈ ចុះ៩៣ ពេលបោះឆ្នោត?

សាម៉ុនៈ អាហ្នឹងក៏នៅ ។

បូលីៈ ពេលណាយើងវាយបាន?

សាម៉ុនៈ ដូចជា៩៨ហើយបានយើងវាយ ។ វាយយកបានហើយ បានមកវាយប្រេកព្រះប្រឡាយនេះមិនជម្មៀសទៅ! ហើយតាមពិតបង្អើល អានេះជារឿងមួយគេហៅថាបច្ចេសយោធា គេបំប្លែងណាំ គេឲ្យមកវាយទេ ប៉ុន្តែផ្អើលនេះក៏ជម្មៀសចេញទៅ ។ តាមពិតគោលបំណងគេ វាយប្រាសាទព្រះវិហារ ។ គេធ្វើទៅវាយត្រពាំងគល់ត្រពាំងអី ភូមិភាគណាំណី សុទ្ធតែកងទ័ពសំខាន់ហើយយកទៅវាយហ្នឹង បើតាមពិត គេមកវាយប្រាសាទព្រះវិហារសោះ ។

បូលីៈ វាយបានទេ?

សាម៉ុនៈ វាយអត់បានទេ ។ វាយប្រាសាទព្រះវិហារ វាយពាជង ។

បូលីៈ ការពារស្អិតតែម្តង ។

សាម៉ុនៈ ព្រោះវា ថាស្អិតក៏ថាបានដែរ មែនទែនទៅយើងមើលភូមិសាស្ត្រ ។ បើចូលបានចូលមកពីជើងហ្នឹងវិញហ្នឹង ។

បូលីៈ ជើង!

សាម៉ុនៈ ចូលមកពីថៃមកវិញហ្នឹង ។ ហើយភូមិសាស្ត្រខាងមុខហ្នឹងឡើងភ្នំមួយចំនួន ។

បូលីៈ ពើយ?

សាម៉ុនៈ ហើយកម្លាំង ខ្ញុំនៅតែប៉ុន្មាន២០ប៉ុន្មាននាក់ ២៦នាក់ហ្នឹង ចុះទៅក្រោមទាំងអស់ ។

បូលីៈ ចុះទៅក្រោម ទៅខាងណាវិញ?

សាម៉ុនៈ ទៅធ្វើការឯក្រោមៗ យើងទៅប្រេក ទៅខាងជាំក្សាន្តទៅអីចឹងទៅណា ។

បូលីៈ ចឹងបានន័យថា កម្លាំងដែលទៅឈរនៅប្រាសាទព្រះវិហារ តែ២០នាក់ជាងទេ?

សាម៉ុនៈ បាទ!

បូលីៈ ហើយបានអាហារណាមកផ្គត់ផ្គង់ពូ?

សាម៉ុនៈ អាហ្នឹងត្រៀមមិនស្មើរទេ ត្រៀមសម្រាប់១០ឆ្នាំអីនោះ ស្បៀងនោះណាម្ហូបអាហារអីហ្នឹងដឹកទាំងយប់ទាំងថ្ងៃ ។

បូលីៈ ដឹកតាមណាមក?

សាម៉ុនៈ ដីថៃ ។

បូលីៈ ហ៊ូ! ដឹកពីដីថៃមកវិញ ។

សាម៉ុនៈ ភ្លេចហើយអន្ទុរយកមកពីថៃ ។

បូលីៈ យកស្តុកនៅណាវិញទៅ? ទុកប្រាសាទ ។

សាម៉ុនៈ មានឃ្លាំងគេក្រោមមួយឃ្លាំងរបស់នេះចាស់ហ្នឹង របស់រដ្ឋាភិបាលចាស់ ។ ផ្ទះគេដាក់អន្ទុរពេញហ្នឹង រាប់សិបតោន ។

បូលីៈ អាកន្លែងគេធ្វើផ្សាររាល់ថ្ងៃហ្នឹង ឬក៏មិនមែន? ឃ្លាំងអន្ទុរ?

សាម៉ុនៈ អត់ដឹងទេ! ខ្ញុំមិនដែលទៅផងហ្នឹង ។

អ្នកជិតខាងៈ(ស្តាប់ពុំបាន)

បូលីៈ ប៉ុននៅខាងជើងប្រាសាទ ឬក៏នៅលើប្រាសាទតែម្តង?

សាម៉ុនៈ នៅឃ្លាំង កាលហ្នឹងដាក់ចេះ ចាំមើលទៅ មិនស្រះ! ផ្លូវឡើងចឹងទៅ អាស្រះយើងចឹងនេះ កន្លែងទីនេះ ពើយខាងនេះ ។

បូលីៈ ចឹងលើផ្សារ លើប្រាសាទដែរ?

សាម៉ុនៈ បើរដ្ឋាភិបាល មិនធ្វើផ្ទះសម្រាប់ភ្ញៀវ សម្រាប់អី ក៏ពួកខ្ញុំដាក់អន្ទុរហ្នឹងតែម្តង ។

បូលីៈ ដាក់អន្ទុហ្នឹងតែម្តង?

សាម៉ុនៈ បាទ!

បូលីៈ ចុះលៃយើងមើលទៅ ពីប្រាសាទព្រះវិហារ យើងមើលទៅឃើញផ្ទះក្រហមមួយនៅលើដីថៃ អាហ្នឹងខ្មែរក្រហមមានឈរជើងនៅហ្នឹង ឬក៏នៅដីថៃយូរហើយ?

សាម៉ុនៈ អាហ្នឹងទើបតែធ្វើដែរទេ ។ ទើបធ្វើជំនាន់រដ្ឋាភិបាលកាន់កាប់ ហើយគេហៅ ខ្មៅដាំង។ សម្រាប់កាលហ្នឹងវាចូលមកប្រាសាទព្រះវិហារអត់បានណា៎ ។ មិនមើលតាមសំណើរយើងពីលើនេះមក គេមកទស្សនកិច្ចអីនៅប្រាសាទព្រះវិហារអីយើងមកពីហ្នឹងមកណា ។ អត់បានដើរមកជិតកន្លែង ។

បូលីៈ ចុះពេលដែលតាម៉ុក គាត់កាន់កាប់រួចហើយ ទាំងត្រពាំងប្រាសាទ ទាំងអន្លង់វែងណាអ៊ីពេលហ្នឹងអ៊ីនៅតែប្រាសាទនៅឡើយ ឬក៏បកមកវិញហើយ?

សាម៉ុនៈ ខ្ញុំត្រលប់មកវិញហើយ ។

បូលីៈ មកណាវិញ? ព្រះប្រឡាយ?

សាម៉ុនៈ បាទ! ខ្ញុំនៅធ្វើការតាមប្រកនេះ ។

បូលី៖ ហើយពេលដែលកម្លាំងយើងមួយចំនួនផ្តាច់ខ្លួន ដូចតា ជុំ តាកែវអីផ្តាច់ខ្លួនរដ្ឋាភិបាល អី
អ៊ុំមានរត់ទៅនៅគេទេ? ឬក៏អ៊ុំនៅខាងក្នុងដែរ?

សាម៉ុន៖ កាលហ្នឹង ខ្ញុំនៅលើប្រាសាទ ព្រោះអីចេញទៅ!

អ្នកជិតខាង៖ ទាក់ទងហ្នឹងប្រាសាទ?

បូលី៖ ប្រាសាទណា?

សាម៉ុន៖ ព្រះវិហារហ្នឹង ។

បូលី៖ ចឹងអត់ឆ្ងាយចុះទេ?

អ្នកជិតខាង៖ នៅទីហ្នឹងមិនឆ្ងាយចូលទេ! សូម្បីតែការកូនក៏អត់បានទៅទេ ។

បូលី៖ ការកូននៅកន្លែងណា?

សាម៉ុន៖ នៅអូរស្មាយ អូរជីកហ្នឹងណា៎ ។

បូលី៖ ពេលការហ្នឹងយ៉ាងម៉េច គេមានស្លៀកពាក់ប្រពៃណីទេ?

សាម៉ុន៖ ស្លៀកពាក់ធម្មតា ។

បូលី៖ មានរាំភ្លេង ស៊ិន ស៊ីសាមុត ទេ រាំវង់អីមានទេ?

សាម៉ុន៖ មាន!

បូលី៖ មានដែរ?

សាម៉ុន៖ បាទ!

បូលី៖ មានជប់លៀងទេ ហូបការ?

សាម៉ុន៖ តាមពិតខ្មែរក្រហមកាលលើងភ្នំហ្នឹងគេហៅរំលាយបក្សកម្មុយនីសកម្ពុជាចោលចឹងទៅណា៎
វាដូចថាយើងដែរណាសេរី សារាប្រិតអីដូចតែគ្នាហ្នឹង ។

បូលី៖ ចុះពេលដែលកម្លាំងតា អ៊ីង លាង ដឹកនាំកម្លាំងរដ្ឋាភិបាលមកវាយទំនប់ដាច់ ព្រះប្រឡាយ
យើងនេះ ពេលហ្នឹងអ៊ុំនៅឯណាវិញ?

សាម៉ុន៖ នៅទំនប់ដាច់ដាច់ រត់ចោលអស់ប៉ុណ្ណឹងហើយ!

បូលី៖ មានវាយតបវិញទេ?

សាម៉ុន៖ មានឯណា បើតាម៉ុកឲ្យកម្លាំងពួកពិការមកកាំភ្លើងឯណា អត់មានទេ ។

បូលី៖ ធ្វើម៉េចទៅអ៊ុំ?

សាម៉ុន៖ អាខ្លះទៅ អាខ្លះគេរត់ចេញទៅ ។ (ស្តាប់ពុំបាន) កាលហ្នឹងនៅតូច ។ លាងហ្នឹងទៅ ខ្ញុំនៅ
ទំនប់ដាច់ កាលហ្នឹងមិនទាន់មានមនុស្សនៅទេ នៅប៉ុន្មានគ្រួសារ ។ ប្រាប់ដែរ ខ្ញុំថាមាន

បញ្ហាប្រាប់គ្នាផងរើយ ហើយយើងមិនបាច់វាយទេណា៎ ព្រោះសភាពការណ៍វាឈានទៅចឹងអស់ហើយ វាទៅចឹងហើយ ។

ប៊ូលី: ចុះចូលហើយ?

សាម៉ុន: បាទ! ចឹងបានខ្ញុំនិយាយជាមួយប្រពន្ធខ្ញុំ ចង់ថាឲ្យ! តាមពិតពួកហ្នឹងវាត្រូវជាមួយរដ្ឋាភិបាលតាំងពីណាពីណីមក តែយើងមិនដឹង ។ ធ្វើអារឿងវាយគ្នារត់លូន ជម្លៀសប្រជាជន របៀបលះ កុំគេចាប់អារម្មណ៍នោះណា៎ ។

ប៊ូលី: ត្រូវគ្នាយូហើយចឹង?

សាម៉ុន: ត្រូវយូរហើយចឹងអាពួកខឹង ផន់! ហើយ(ស្តាប់ពុំបាន) គេត្រូវគ្នាយូរហើយ ប៉ុន្តែគ្រាន់តែថា ប៉ុល ពតមិនដឹងរឿង ។

ប៊ូលី: មិនដឹងរឿងថាយើងត្រូវគ្នា?

សាម៉ុន: បាទ! អាហ្នឹងខ្មែរតាម៉ុកទេដែលគេត្រូវទាក់ទងគ្នា ។

ប៊ូលី: ចុងតាម៉ុក ដឹងទេថា ក្រុមតា ផន់ អីត្រូវជាមួយរដ្ឋាភិបាល?

សាម៉ុន: យើងដឹងតែកម្លាំងគាត់ កម្លាំងតាម៉ុក ។

ប៊ូលី: ធ្វើម៉េចទៅបានដឹងថាតាម៉ុក(ស្តាប់ពុំបាន)?

សាម៉ុន: តាម៉ុកហ្នឹងផែនការ ចង់(ស្តាប់ពុំបាន) ជាមួយប៉ុលពតទេ ចូលសមាហរណកម្ម ហើយហ្នឹងណាតាពិតចឹងឯង គ្រាន់ថាទៅវាអត់រួច ។ ដល់អត់រួចចឹងទៅវាបែកបាក់ផ្ទៃក្នុង វា រញ៉េរញ៉ៃលិចកើតទៅ ចាប់មេមដឹកនាំខ្លាំងៗទៅណា ។

ប៊ូលី: ចឹងដូចជាមួយចង់ចុះចូលខ្លាំងហើយមើលទៅ?

សាម៉ុន: បាទ! អាហ្នឹងដូចជាពិបាកអាហ្នឹង ខ្ញុំមើលទៅប្រវត្តិកេពាក់ព័ន្ធតាំងពីក្នុងព្រៃនោះ តាមខ្ញុំមើលប្រវត្តិក្នុងព្រៃនោះ ។ កម្លាំងមិនមែនជាកម្លាំងកម្មុយនីសសុទ្ធទេ ចូលតស៊ូសម័យនោះដូចយើងឥលូវនោះគណបក្សច្រើនចឹងណា៎ វាដូចតែគ្នាចឹងច្របូលច្របល់ មិនដឹងឯណាឯណី ។ ចឹងបានថាសម័យ៣ខែ២០ថ្ងៃ សម្លាប់មែនប៉ុន្តែ មិនមែនលើទៅបញ្ហាសម្លាប់ទេ ។ សម្លាប់ស្អប់ស្រលាញ់ បក្សពួកអានេះ បក្សពួកអានោះចឹងទៅណា៎ ។

ប៊ូលី: នរណាយកទៅតាមមើលអ៊ុំ?

សាម៉ុន: បេះជិនាន់នោះវាមិនមានខ្មែរអាមេរិច ខ្មែរចិន ខ្មែរយួនអី ដូចតែគ្នាចឹងណា៎! ឥលូវដូចគណបក្សប្រឆាំងអីចឹង គេមិនខ្មែរអាមេរិច! បើសិនមានសិទ្ធវាយចោលដូចសម័យមុនវាយចោលស្អុយព្រៃ ដូចតែគ្នាហ្នឹង និយាយចឹងវាមិនមែនខ្មែរក្រហមសុទ្ធទេណា៎ តស៊ូនោះ

ហើយដល់ពេលឈ្នះ៧៥ ហើយប៉ុល ពតកាន់អំណាចគេម៉េចសុខចិត្ត គេតស៊ូដែរ គេម៉េចសុខចិត្តបើឯង កាន់អំណាចតែឯង។ មិនមែនចេះតែរកលះចោទចាខ្ញាំងកើតគ្នាយកទៅវាចោល មិនដឹងបននោះណា៎ គេមិនដឹងមុខនោះណា៎។ ចឹងបានខ្ញុំជាមួយ សេង ធារី និយាយត្រូវគ្នា កំពុងតែស្វែងរកការពិតនរណាឃាតករពិតនោះ រកវាអត់ឃើញទេណា៎។

បូលី៖ គាត់ថាម៉េច សេង នារី?

សាម៉ុន៖ គាត់ថាសម័យ៣ឆ្នាំ ៨ខែ ដូចបងឯងចឹង មិនថាខ្មែរសុទ្ធទេ ព្រោះទៅវេទិការស្វែងរកការពិត ខ្ញុំនិយាយតែ២,៣មាត់។ ខ្ញុំថាសម័យ៣ឆ្នាំ៨ខែ ២០ថ្ងៃនោះ សម្លាប់! ហើយរបបនោះ មិនមែនរបបដែលឃោឃៅតាមខ្ញុំដឹង ប៉ុន្តែរឿងមុខមាត់បុណ្យសក្កិបុគ្គលទេដែលវាធ្វើហ្នឹង។ តាមគោលបំណងរបស់ប៉ុល ពត មិនមែនរំដោះប្រជាជនហើយយកមកសម្លាប់ចោល វាមិនត្រូវរឿង។ ចឹងសេង ធារីគាត់និយាយថា យល់ដូចលោកគ្រូឯងដូចខ្ញុំដែរ។ ខ្ញុំថាសម័យនោះមិនមែនប៉ុល ពតបញ្ជាឲ្យសម្លាប់ណា៎ តែគ្នាវានោះ ចុះជំនាន់យើង ខ្ញុំនិយាយតិចចុះមួយជំនាន់នោះយើង គណៈតំបន់ ភូមិភាគអីស្តេចត្រាញ់អស់រលីងហើយ មានស្តាប់នរណាមិនចឹង! យើងគិតចឹងទៅឲ្យវាយល់ទាំងអស់គ្នា ព្រោះខ្ញុំគិតថាសម័យនោះ ច្របូលច្របល់គ្នា គ្មានរើសមុខទេ ដូចពាក្យគេថាត្រឹមមេក្រុមគេសម្លាប់មនុស្សបាន ប៉ុន្តែដោយឡែកអង្គភាពខ្ញុំ សួរគ្រួសារខ្ញុំអត់ដែលឃើញសម្លាប់គ្រួសារអីបានមួយទេ។ បាទ! ខ្ញុំនៅហ្នឹងព្រោះតំបន់ហ្នឹងវា កងទ័ពនៅពាសពេញ មាននរណាវាមនុស្សចោល អត់ហានទេណា៎។ ពួកសហករណ៍ ពួកអី មេឃុំ ពួលឈ្លបអី អត់ហានទេ! បាទនៅតំបន់ខ្ញុំធ្វើការនៅហ្នឹងអត់ មាននរណាហានសម្លាប់ប្រជាជនទេ។ មានតែមន្ទីរ ពួកយើងខាងបញ្ហាលិចកើត ចឹងទៅបានវាមិនដោះដូរមេដឹកនាំខាងមណ្ឌលគិរីហ្នឹង ខាងបូព៌ាជំនាន់ហ្នឹង។ អាហ្នឹងដូច មណ្ឌលគិរី ដូចជាជាប់ត្បូសានដែរទេ?

បូលី៖ មណ្ឌលគិរីនៅត្បូសាន។

សាម៉ុន៖ បូព៌ាដែលក្រចេះអីទេណា៎?

បូលី៖ បាទ! ទៅក្រចេះខ្លះ ស្រុកនេះ កំពង់ចាម ព្រៃវែងស្វាយរៀង។ ខ្ញុំគិតថាជំនាន់នោះបើតាមខ្ញុំចេះតែសើបៗ តាមមិត្តភក្តិវានៅ យើងនៅខាងបូព៌ានោះណា៎ សម្លាប់មនុស្សរង្គាលបូព៌ាហ្នឹង។ គិតទៅឆ្នាំ៧៧ ហ្នឹងហើយខ្លាំង ចឹងបានន័យថា កាលនោះជំនាន់ហៅរដ្ឋៗ។ កាលហ្នឹងរដ្ឋជម្លៀសប្រជាជនអីពោធិ៍សាត់បាត់ដំបង គេវាមានដីទូលំធំ ធ្វើស្រែធ្វើចម្ការអីណា មានស្រូវមានអី ហូបចុកមានអី។ ជម្លៀសអាហ្នឹងមកមានបន្តប់ភ្នាក់ងារ

តាមសម្លាប់យើងពោធិ៍សាត់នេះទៀត បាត់ដំបងទៀត វាបន្កប់គ្នាវា មិនធម្មតាទេ! ចិនចម្ងល់ហ្នឹងយើងនិយាយមែនទែនទៅបូព៌ា គេថាខ្មែរយួនអីចិនទៅណា៎ៗ បាទខ្មែរយួនអីចិនទៅបានថាស្អីមេភូមិភាគហ្នឹង បាត់សោភឹមៗ សោភឹម បើនៅហ៊ុន សែននេះគមានទេ នាយករដ្ឋមន្ត្រីនេះទេៗ សោភឹមនោះមេធំ មិនមែនលេងទេ! ហើយដល់ចិនខាងខ្មែរអាមេរិចអី មិនរើបម្រាស់អីមិចិន! ជំនាន់ហ្នឹងវាមិនចាប់ ដូចស្អីកុយ ធួនគេណា៎ៗ កុយ ធួន ហៅធុចៗណា៎ ភូមិភាគឧត្តរ គាត់គណៈភូមិភាគឧត្តរហ្នឹង ដល់ក្រោយមកបានគ្រាប់គ្រងខាងស្អីដូចជា!

សាម៉ុនៈ ខាងផ្នែកពាណិជ្ជកម្ម! ហើយដូចវ៉ន វេតអីហ្នឹង មិនមែនលេងណា៎ៗ ចិនបានខ្ញុំពិបាកសន្និដ្ឋានណា៎ អាជំនាន់ហ្នឹងវាខ្លះខ្មែរចិន អាខ្លះខ្មែរយួន អាខ្លះខ្មែរអាមេរិច ខ្លះខ្មែរសូវៀត មិនដឹងជំនាន់ណាៗទេ យាប់ណាៗ ហើយបើយើងនិយាយ នួន ជា គាត់ ប្រវត្តិគាត់តស៊ូថៃ នៅខាងថៃក្រហមអីហ្នឹងៗ អាហ្នឹងមិនខ្មែរថៃអីទៀតហើយ ច្របូកច្របល់ចិនៗ ចិនបានយើងពិបាកណាស់ យើងពិបាកសន្និដ្ឋាន នរណាចេញមុខដែលសម្លាប់មនុស្សៗ អត់! រកមុខអត់ឃើញ ចិន៩៩នេះយើងទៅស្រុក បងប្អូន មីងមារអី គេយកវាយចោល ហើយប៉ាខ្ញុំ ឪពុកខ្ញុំអី នៅតែមួយថ្ងៃទៀតគេយកទៅវាយចោលណា៎!

បូលីៈ បាទ!

សាម៉ុនៈ មិនមែនលេងទេណា៎យួន! គេថាបើយួនឈ្លានពានម៉្យាងទៅ រស់ភាគច្រើនយួនចូលមករស់បានច្រើនដែរៗ អាហ្នឹងវាចិន ព្រោះចោទទៅជាប៉ាខ្ញុំហ្នឹង១៧មេសាអីណាអីណី តែតាពាសចិនទៅណាៗ គេប្រុងមកយក យើងទៅវាយចោល ហើយធាតុពិតណា ខ្ញុំធ្វើចេះ ចំណុចខ្លាំងរបស់វា វាត្រូវកម្ទេចប៉ុល ពតណា៎ៗ ត្រូវកម្ទេចរបបប៉ុល ពត សំខាន់! វាធ្វើឲ្យបែកបាក់នៅក្នុងផ្ទៃក្នុងៗ មួយកាប់សម្លាប់ ២ចាប់ដាក់គុកដាក់ច្រវ៉ាក់ចិនទៅ ធ្វើទារុណកម្មទៅវាអត់បាយអត់ទឹកអីចិនទៅណា៎ ព្រោះនិយាយហើយថាបើសិនជាវាយប៉ុល ពត ភ្លាមវាយពុំបានទេ ព្រោះកម្លាំងវានៅខ្លាំងៗ បើមិនខ្លាំងយ៉ាងម៉េច បើវាស៊ីបាយគ្រប់គ្រាន់ ដល់តែក្រោយមកវាមិនកាឡៃ វាកើតបបរ! ប៉ុន្តែគ្រោះល្អអង្គភាពនោះខ្ញុំអត់ដែរឃើញស៊ីបបរ បើ៣ពេលដឹងតែ៣ពេល ប៉ុន្តែបើខ្លះខាតអង្ករអីយើងមានបាយលាយពោត លាយដំឡូងអីចិនទៅណា៎ ប៉ុន្តែគ្រាន់តែថាវាមិនថ្នាក់ស៊ីបបរយូរ វាល់វែកវាល់អីយើងមិនដែលឃើញ ហើយទី២នោះដូចខ្ញុំនិយាយខាងដើមមិញ វាមិនដែលឃើញយកមនុស្សទៅវាយចោល វាអត់ដែរឃើញ វាមានចេះដូចថាខុសឆ្គងអី សីលធម៌អី អាច

យកទៅអប់រំណ៎ា មិនមែនដាក់គុកដាក់ច្រវ៉ាក់ទេ យកទៅអប់រំ ៗ ធ្វើការងារធម្មតាហ្នឹងណាកែប្រែទៅ ក៏វាបានទៅអគ្គភាពពេញទៅណ៎ា ប៉ុន្តែសម័យដែលយួនបុកនោះទៅអគ្គភាពវិញទាំងអស់ទៅណ៎ាពួកហ្នឹង ៗ ហើយសម័យនោះ ខ្ញុំជួបពួកខាងបូព៌ាឡើងមកភ្នំឈ្មោះគ្នា ព្រោះជារឿងចិនមែន ស្រេចតែគេយកបក្សកុម្មុយនីសយើងដឹងតែអាចុងក្រោយវាប៉ុន្មាននោះប្រថុយទៅវាស្រែក បក្សពលករវៀតណាមតែម្តងទៅ កុំឲ្យពិបាក ៗ ស្រែកចិនទៅក៏រស់មកជួបខ្ញុំ១០០៣អី ពួកហ្នឹង ប៉ុន្តែឥលូវគាត់ស្លាប់ហើយ ៗ គាត់ស្រែកចិនវារស់ អាហ្នឹងរួចខ្លួន ចិនបានថាវិធីសាស្ត្រ វាមិនដឹងជាយ៉ាងណ៎ា ៗសម័យនោះប្របូកប្របល់រកចាប់ថ្នាក់នរណាមួយមិនបាន ៗ ហើយដល់ក្រោយមក គេថាខាងនិរតីសម្លាប់មនុស្ស អើកាលហ្នឹងនេះហើយមិនយកពួកនិរតីមកគ្រប់គ្រងតាមខេត្តតាមស្រុកអីទៅណា ៗ តាមពិតគ្នាមិនដឹងទេ អាពួកអស់ហ្នឹងធ្វើចៅហ្វាយស្រុក ខេត្តយើងនៅ ប៉ុន្តែអាខ្លះស្លាប់ហើយ ៗ អាមួយនោះនៅ ធ្វើស្មៀននៅផ្សារ បោកខោឲ្យគេមានដឹងថាគេយកមនុស្សទៅវាយចោលឯណា ចោទគ្នា! ខ្ញុំដាក់ស្តែង ខាងខ្ញុំអត់មានទេ អត់ឃើញមានវាយចោលទេ ហើយទើបខ្ញុំឆ្លងមកលិចទេ អត់ដឹងរឿង ៗ ឆ្លងមកនេះប្រជាជនគាត់ គក់អាខ្មៅអាវខ្មៅ ក៏រត់ពួនណ៎ា ចាប់! ត្រូវការចាប់ ដល់តែខ្ញុំមកដល់សេកុង គេហៅភូមិអីទេនិយាយពីស្រូវ គរដូចភ្នំចិន! ឲ្យគាត់យកទៅកិន យកទៅបុកហូបអត់ហាន អូយ!សម្បើមដែណាស់ណ៎ា ៗ ខ្ញុំថាអើយជំនាន់នោះធ្វើឲ្យមនុស្សអស់តែស្អីនោះមិនហាន ដូចថាឥលូវអ៊ីងងទៅខ្លាចអី បើយៀកណាមគេវាយចូលមក រំដោះអស់រលីងឥលូវហើយ ទៅខ្លាចអីហូបចុក ខ្លាចអីពួកអាមួយក្បាល ២ក្បាលហ្នឹង ៗ អត់ៗហាន! ដល់សម័យក្រោយចាស់គាត់សួរ ម៉េចបានឃើញពួកខ្ញុំរត់ ខ្ញុំថាអាពួកនេះសម្លាប់ឃោឃៅណាស់ ៗ ខ្ញុំថាឪឲ្យខ្ញុំនៅបរវេននៅព្រំដែន ខ្ញុំអត់ដឹងគេសម្លាប់នោះទេ ៗ ហ៊ូវាធ្វើចិនតា បានវាបែកបាក់ផ្ទៃក្នុងខ្ទេចខ្ទីអស់ ហើយមែនទែនទៅសម្លាប់គ្រួសារទាហាន ហ្នឹងឲ្យទាហាន ទាហានបាក់ឃើញចិនតែម្តង? ធ្វើបាបតែអាគ្រួសារ ដែលមកធ្វើកងទ័ពចិនឯង ដល់ក្រោយកើតចេះកើតចុះ ១៧មេសាលិចកើតទៅដាក់ស្តែង ដូចបងប្អូនខ្ញុំ ទៅឡើងវាលណ៎ាខ្ញុំ ទៅយំតែម្តងបាត់បងប្អូន មិនមែនធម្មតាគូខ្ញុំអីនោះទេ គេយកមកភ្ជួរស្រែ គេយកមកវាយចោលកណ្តាលថ្ងៃត្រង់ ៗ ខ្ញុំបែកសាច់ញាតិច្រើន បងប្អូនខ្ញុំអស់ ខ្ញុំក៏កំពុងស្វែងរកអាណាអ្នកសម្លាប់មនុស្ស ៗ គ្មានគាត់ក្តី កាត់អី យើងមានមើល បើសិនជាធ្វើតាម គោលការណ៍មាគ៌ាទៅតាមប៉ុល ពត មិនវេទនាចេះទេ ៗ ទិសដៅរបស់គាត់ច្បាស់ណាស់ ខ្ញុំជឿតែម្តង

ជឿអាសត្វខ្មែរយើងវាមុខមាត់បុណ្យសក្តិ ដណ្តើមគ្នាអំណាចគ្នា ។ មកពីណ្តើមអំណាចគ្នាបានប្រទេស មិនចេះសុខ មិនចេះសាន្ត សង្គ្រាមបែកបាក់កាប់សម្លាប់គ្នារឿងចឹងហើយ ។ សម័យណា ក៏ដូចសម័យណា មិនចេះតែតាមដាន ព្រោះអាសម័យហ្នឹង ខ្ញុំចេះតែតាមដានហើយ បើសម័យស្តេចផងដណ្តើមរាជ្យគ្នា មិនមែនតែសាប់គ្នាវាណា៎ សាប់រាស្ត្រ ហើយអាពួកឥលូវវាដណ្តើមអំណាច ដល់ចឹងខ្ញុំមើលឃើញចឹងទៅ ពួកអាធំៗវាសាប់អីវា សាប់តែយើងប្រជាជនតូចតាច អាហ្នឹងដូចភាសាយើងថាដូចស្មៅចឹងណាប្រជាជន! ដើរជាន់ត្រង់ណាដួលត្រង់ហ្នឹង ឬក៏ប្រជាជនរងគ្រោះដែរ ព្រោះសម័យនោះយើងមិនមែនជាអ្នកនយោបាយ យើងបម្រើនយោបាយ ការងារគេកាប់សម្លាប់យើង មិនដឹងរឿងអីទាំងអស់ ។ តាមខ្ញុំដឹងល្បៀងចាប់ពួកកវាបានមួយ ចាប់អាពួកស្មោះត្រង់ មិនដឹងអីហ្នឹងរាប់រយចឹងណា៎អូន ។ ឧទាហរណ៍ថាពួក ប៉ុល ពតនោះវាចាប់បានមេដឹកនាំនោះវាមួយ ខ្ញុំវាអានោះវាដើរឆ្លើយវាអ្នកល្អ ។ ដល់ចឹងវាចេះតែតៗគ្នា សម្លាប់អត់រើសមុខមិនដឹងបន ទៅជាដេរពេញទាំងភូមិខ្ញុំ នរណាសម្លាប់ប្អូនអញ អ្នកស្រុកហ្នឹងគាត់ប្រាប់ថាអើយវាមិននៅទេ ។ ហើយគ្រួសារខ្ញុំនៅ៧៧ មករតនគិរីហ្នឹងហើយគេថាអត់រស់ទេ ព្រោះឈ្លបហ្នឹងគេជូនមក ។ ៩៨ហ្នឹង សមាហរណកម្មហ្នឹង ៩៩ខ្ញុំទៅ! ទៅមានស្អីយមគ្រប់តែគ្នា ថាប្រហែលជាសាប់បាត់ទៅហើយ ។

បូលី: មិននឹកស្មានថាបានជួបគ្នាវិញទេណា៎អ៊ុំណា៎?

សាម៉ុន: បាទ! ធ្វើការឆ្លងកាត់រាប់សិបឆ្នាំមកហើយ ។

បូលី: ខ្ញុំដូចជារំខានអ៊ុំយូរដែរហើយ ហើយដល់តែម៉ោងអ៊ុំពិសារបាយដែរ ពេលដែលអ៊ុំ ម៉ោង១ទៅហើយម៉ោង ចឹងអ៊ុំដូចជាអរគុណច្រើន ដែលបានជជែកលេងពិភាក្សា ។

«ចប់»